ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២០ លេខ៣៧ ត្រីមាសទី០២ ឆ្នាំ២០២០

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារធាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជឱង្ការព្រះមហាក្សត្រ

១~ព្រះរាជក្រម

២៨-៣-២០២០	-ព្រះរាជក្រម នស/រកម/០៣២០/០១៤ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន	៤៤៦៣

២~ព្រះរាជក្រឹត្យ

៩-៤-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៤២០/៤៣៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ៥ រូប	៤៥៣៣
៩-៤-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៤២០/៤៤០ ស្តីពី ការតម្លើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១០ រូប	៤៥៣៤
៩-៤-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៤២០/៤៤១ ស្តីពី ការតម្លើងឋានន្តរស័ក្តិឧត្តមអគ្គានុរក្សពន្ធនាគារ ដល់មន្ត្រីពន្ធនាគារ ចំនួន ៤ រូប នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ	៤៥៣៦

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២១-៤-២០២០	-អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត	៤៥៣៧
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២០ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា	៤៥៤១
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២១ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សា	៤៥៤៣
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៤៥៤៤
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៤៥៤៥
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៤៥៤៦
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៤៥៤៧
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៤៥៤៨
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២៧ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ	៤៥៤៩
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ	៤៥៥១
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣២៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៤៥៥៥

៣០-៣-២០២០	-អនុក្រឹត្យលេខ ៣៣០ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ	៤៥៥៦
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣៣១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	៤៥៥៨
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣៣២ អនក្រ.តត ស្តីពី ការជូនមេដាយស្តាបនាជាតិ	៤៥៥៩
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣៣៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	៤៥៦១
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣៣៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	៤៥៦៣
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣៣៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ	៤៥៦៤
៣០-៣-២០២០	-អនុក្រឹត្យលេខ ៣៣៦ អនក្រ.តត ស្តីពី ការជូនមេដាយស្តាបនាជាតិ	៤៥៦៦

២~សេចក្តីសម្រេច

២-៤-២០២០	-សេចក្តីសម្រេចលេខ ៣៤ សសរ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩(**COVID-19**)	៤៥៦៩
៣-៤-២០២០	-សេចក្តីសម្រេចលេខ ៣៥ សសរ ស្តីពី ការចាត់តាំងរដ្ឋលេខាធិការប្រចាំការ	៤៥៧១

III~ការងារបណ្តារក្រសួង

១.ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២២-១-២០២០	-ប្រកាសលេខ ១២៤៥ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម	៤៥៧២
១០-២-២០២០	-ប្រកាសលេខ ១៤៩៤ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល	៤៥៧៣

២.ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

២០-១-២០២០	-ប្រកាសលេខ ០០០៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០០៧ រថ.អប្រក.លអ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២០	៤៥៧៤
២០-១-២០២០	-ប្រកាសលេខ ០០០៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០០៩ រថ.អប្រក.លអ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២០	៤៥៧៨
២៣-១-២០២០	-ប្រកាសលេខ ០០១១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លេខ ០០១១ រថ.អប្រក.លអ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០២០	៤៥៨២

៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

១៦-១២-២០១៩	-ប្រកាសលេខ ១៩០ កយ.ប្រក/១៩ ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ	៤៥៨៦
២៤-២-២០២០	-ប្រកាសលេខ ០៤៥ កយ.ប្រក/២០ ស្តីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សបន្ត	៤៥៨៧

ព្រះរាជក្រម

ឧស/រកម/០៣២០/ ០១៤ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិង្ករាធរមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី១ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើពិធីសារទី១
ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

មាត្រា១ .–

អនុម័តយល់ព្រមលើពិធីសារទី១ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ានដែលធ្វើនៅរដ្ឋធានីហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២ .–

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ។

មាត្រា៣ .–

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ៥កើត ខែជេដ្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០២០

ន សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ពិធីសារទី១ធ្វើវិសោធនកម្ម
កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

រដ្ឋាភិបាលព្រុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ជាប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ហៅកាត់ជារួមថា "បណ្តាប្រទេសសមាជិក" ឬតែមួយហៅថា "ប្រទេសសមាជិក"។

ដោយរំលឹកឡើងវិញ នូវកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA) ដែលបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ នៅភ្នំពេញ ប្រទេសកម្ពុជា;

ដោយយល់ដឹង អំពីគោលបំណងដែលបានព្រមព្រៀងគ្នាក្នុងការដាក់ឱ្យអនុវត្តវិធានដើមកំណើត (ROO) ដែលឆ្លើយតបទៅនឹងការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងដំណើរការផលិតកម្មសកល ដើម្បីសម្រួលពាណិជ្ជកម្មនិងការវិនិយោគក្នុងចំណោមបណ្តាប្រទេសជាសមាជិក លើកកម្ពស់បណ្តាញផលិតកម្មក្នុងតំបន់ ជំរុញការអភិវឌ្ឍសហគ្រាសខ្នាតតូចនិងមធ្យមនិងបន្ថយគម្លាតនៃការអភិវឌ្ឍ និងជំរុញបង្កើនការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ដូចដែលបានបង្កើតឡើងក្រោមផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន២០១៥។

ដោយរំលឹកឡើងវិញថា ដើម្បីសម្រេចបានគោលបំណងនេះ ប្រមុខដឹកនាំបានឯកភាពក្នុងការធ្វើឱ្យនីតិវិធីប្រតិបត្តិនៃការបញ្ជាក់ដើមកំណើត មានភាពងាយស្រួលនិងធានាឱ្យបាននូវការរីកចម្រើនជានិរន្តរ៍។

ដោយទទួលស្គាល់ថា ផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន២០២៥ ចែងថា វិធានដើមកំណើតដែលបានអនុវត្តដោយប្រទេសជាសមាជិកត្រូវមានភាពសាមញ្ញ ភាពងាយស្រួលក្នុងការធ្វើពុរកិច្ចនិងសម្រួលពាណិជ្ជកម្ម ដើម្បីផ្តល់ផលប្រយោជន៍ដល់ពាណិជ្ជកម្មក្នុងតំបន់ ជាពិសេសការចូលរួមរបស់សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ដើម្បីជំរុញលើកទឹកចិត្តសហគ្រាសទាំងនោះក្នុងការពង្រីក ធ្វើឱ្យប្រសើរឡើង និងធ្វើឱ្យការតភ្ជាប់គ្នាក្នុងតំបន់មានលក្ខណៈស៊ីជម្រៅ។

ដោយឆ្លាងថា ដើម្បីអនុវត្តជាផ្លូវការនូវគម្រោងស្វ័យបញ្ជាក់ដើមកំណើតក្នុងតំបន់។

ដោយទទួលស្គាល់ថា ដើម្បីធ្វើវិសោធនកម្មមាត្រា៣៨ នៃATIGA ក្នុងការផ្តល់ជាមូលដ្ឋានគតិយុត្តសម្រាប់គម្រោងស្វ័យបញ្ជាក់ដើមកំណើតក្នុងតំបន់។

ដោយកត់សម្គាល់ថា មាត្រា៩៤ (១) នៃ ATIGA ចែងថា ការធ្វើវិសោធនកម្មលើបណ្តាបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអាចធ្វើឡើងបានតាមរយៈការព្រមព្រៀងទៅវិញទៅមក នៅពេលដែលមានការសរសេរជាលាយលក្ខណ៍អក្សរដោយបណ្តាប្រទេសជាសមាជិក។

បានព្រមព្រៀងដូចតទៅនេះ ÷

មាត្រា១

វិសោធនកម្មមាត្រា៣៨ (វិញ្ញាបនបត្របញ្ជាក់ដើមកំណើត)

មាត្រា៣៨ នៃ ATIGA នឹងត្រូវដាក់ជំនួសដោយ÷

"មាត្រា៣៨

សំអាងដើមកំណើត

ការអះអាងថាទំនិញត្រូវតែទទួលស្គាល់សម្រាប់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូល ត្រូវភ្ជាប់មកដោយសំអាងដើមកំណើតស្របតាមនីតិវិធីប្រតិបត្តិនៃការបញ្ជាក់ដើមកំណើតដែលមានចែងនៅក្នុងឧបសម្ព័ន្ធទី៨។"

មាត្រា២

អនុសាសនប្បញ្ញត្តិ

១. ពិធីសារនេះត្រូវបានបង្កើតឡើងជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន។

២. ពិធីសារនេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីថ្ងៃដែលសមាជិកទាំងអស់បានជូនដំណឹងទៅអគ្គលេខាធិការដ្ឋានអាស៊ាន នៅពេលដែលបញ្ចប់នីតិវិធីផ្ទៃក្នុង។ ការជូនដំណឹងនេះមិនគួរឱ្យលើសពីមួយរយប៉ែតសិប (១៨០) ថ្ងៃ បន្ទាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះឡើយ។

៣. អគ្គលេខាធិការដ្ឋានអាស៊ាន ត្រូវជូនដំណឹងជាបន្ទាន់ដល់សមាជិកទាំងអស់ស្តីពីការជូនដំណឹង ដោយយោងទៅតាមកថាខណ្ឌទី២នៃមាត្រានេះ។

៤. ពិធីសារនេះត្រូវបានតម្កល់នៅអគ្គលេខាធិការដ្ឋានអាស៊ានដែលជាអ្នកត្រូវបញ្ជូនជាបន្ទាន់ នូវច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវមួយច្បាប់ដល់សមាជិកនីមួយៗ។

ដើម្បីជាសក្ខីភាព ហត្ថលេខីខាងក្រោមដែលបានទទួលសិទ្ធិប្រទានពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន។

ធ្វើនៅ រដ្ឋធានីហាណូយ ប្រទេសវៀតណាម ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ជាច្បាប់ដើមតែមួយ ជាភាសាអង់គ្លេស។

សម្រាប់រដ្ឋាភិបាលព្រុយណេដារ៉ូសាឡឹម

.....

សម្រាប់រដ្ឋាភិបាលកម្ពុជា

.....

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

.....

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

.....

សម្រាប់រដ្ឋាភិបាលម៉ាឡេស៊ី

.....

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

.....

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

.....

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

.....

សម្រាប់រដ្ឋាភិបាលព្រះរាជាណាចក្រថៃឡង់ដ៍

.....

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

.....

FIRST PROTOCOL TO AMEND THE ASEAN TRADE IN GOODS AGREEMENT

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (ASEAN), hereinafter collectively referred to as "Member States" or singularly as "Member State";

RECALLING the ASEAN Trade in Goods Agreement (ATIGA) signed in Cha-am, Thailand on 26 February 2009;

CONSCIOUS of the agreed objective of putting in place rules of origin (ROO) which are responsive to the dynamic changes in global production processes so as to facilitate trade and investment among Member States, promote a regional production network, encourage the development of small and medium enterprises and the narrowing of development gaps, and promote the increased usage of the ATIGA, as established under the ASEAN Economic Community Blueprint 2015;

RECALLING that, to meet this objective, the Leaders agreed to simplify the Operational Certification Procedure for the ROO and ensure its continuous enhancement;

RECOGNISING that the AEC Blueprint 2025 states that ROO implemented by Member States should be simplified, business-friendly and trade-facilitative, to benefit the region's trade, in particular the participation of micro, small and

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

medium enterprises to encourage them to expand, upgrade, and deepen their linkages within the region;

DESIRING to formally implement a regional self-certification scheme;

RECOGNISING the need to amend Article 38 of the ATIGA to provide the legal basis for the regional self-certification scheme;

NOTING that Article 94(1) of the ATIGA provides for any amendments to the provisions of the Agreement to be mutually agreed upon in writing by the Member States,

HAVE AGREED AS FOLLOWS:

Article 1
Amendment to Article 38 (Certificate of Origin)

Article 38 of the ATIGA shall be substituted with the following:

"**Article 38**
Proof of Origin

A claim that a good shall be accepted as eligible for preferential tariff treatment shall be supported by a Proof of Origin in accordance with the Operational Certification Procedures as set out in Annex 8."

Article 2
Final Provisions

1. This Protocol shall form an integral part of the ATIGA.

2. This Protocol shall enter into force on the thirtieth day after the date on which all Member States have notified the

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

Secretary-General of ASEAN of the completion of their internal procedures. Such notifications should not take more than one hundred and eighty (180) days after the date of signing of this Protocol.

3. The Secretary-General of ASEAN shall promptly notify all Member States of the notifications referred to in paragraph 2 of this Article.

4. This Protocol shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof to each Member State.

IN WITNESS WHEREOF, the undersigned, being duly authorised thereto by their respective Governments, have signed the First Protocol to Amend the ASEAN Trade in Goods Agreement.

DONE at Ha Noi, Viet Nam this Twenty - second Day of Janvary in the Year Two Thousand and Nineteen, in a single original copy in the English language.

For Brunei Darussalam:

.....

For the Kingdom of Cambodia:

.....

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

For the Republic of Indonesia:



.....

For the Lao People's Democratic Republic:



.....

For Malaysia:

.....

For the Republic of the Union of Myanmar:



.....

For the Republic of the Philippines:

.....

For the Republic of Singapore:

.....

For the Kingdom of Thailand:

.....

For the Socialist Republic of Viet Nam:

.....

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

ឧបសម្ព័ន្ធទី៨
ស្តីពីនីតិវិធីប្រតិបត្តិនៃការបញ្ជាក់ដើមកំណើត
សម្រាប់ចិញ្ចានដើមកំណើត ក្រោមជំពូកទី៣

សម្រាប់គោលបំណងក្នុងការអនុវត្តវិធានដើមកំណើត ដូចមានចែងក្នុងជំពូកទី៣នៃកិច្ចព្រមព្រៀងនេះ នីតិវិធីប្រតិបត្តិខាងក្រោមស្តីពីការចេញនិងពិនិត្យផ្ទៀងផ្ទាត់សំអាងដើមកំណើតនិងបញ្ហារដ្ឋបាលពាក់ព័ន្ធដទៃទៀតនឹងត្រូវបានប្រតិបត្តិតាម។

ចិញ្ចានទី១
និយមន័យ

(ក) **ASW** (ASEAN Single Windows) មានន័យថា បញ្ហរតែមួយអាស៊ាន ដូចដែលបានចែងក្នុងមាត្រា៥ (ក) នៃ ពិធីសារស្តីពីក្របខណ្ឌច្បាប់ដើម្បីអនុវត្តបញ្ហរតែមួយអាស៊ាន (PLF)

(ខ) **សំអាងដើមកំណើតបន្ត (Back-to-back Proof of Origin)** មានន័យថា ឯកសារសំអាងដើមកំណើតដែលចេញដោយប្រទេសសមាជិកអន្តរការីនាំចេញ ផ្អែកលើសំអាងដើមកំណើតដែលចេញដោយប្រទេសសមាជិកនាំចេញដំបូង

(គ) **អ្នកនាំចេញដែលមានការទទួលស្គាល់ (Certified Exporter-CE)** មានន័យថា អ្នកនាំចេញដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិវេទន៍ដើមកំណើតលើដើមកំណើតទំនិញដែលបាននាំចេញ

(ឃ) **អាជ្ញាធរមានសមត្ថកិច្ច** មានន័យថា អាជ្ញាធររដ្ឋាភិបាលនៃប្រទេសសមាជិកនាំចេញដែលបានចាត់តាំងក្នុងការផ្តល់សិទ្ធិទៅ CE

(ង) **វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) តាមប្រព័ន្ធអេឡិចត្រូនិក (e-Form D)** មានន័យថា វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមគោលការណ៍ណែនាំអំពីដំណើរការនិងនីតិវិធីក្នុងការអនុវត្តវិញ្ញាបនបត្របញ្ជាក់ដើមកំណើតក្នុងទម្រង់ D តាមប្រព័ន្ធអេឡិចត្រូនិកក្រោម ATIGA និងត្រូវបានបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិកវាងប្រទេសសមាជិកតាមរយៈបញ្ហរតែមួយអាស៊ាន (ASW) ស្របទៅតាមបទប្បញ្ញត្តិសន្តិសុខដែលបានចែងក្នុងមាត្រា៩នៃពិធីសារស្តីពីក្របខណ្ឌច្បាប់ដើម្បីអនុវត្តបញ្ហរតែមួយអាស៊ាន (PLF)

(ច) **អ្នកនាំចេញ** មានន័យថា រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានទីតាំងនៅក្នុងទឹកដីនៃប្រទេសសមាជិកមួយដែលបានធ្វើការនាំចេញទំនិញ

(ឆ) **អ្នកនាំចូល** មានន័យថា រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានទីតាំងនៅក្នុងទឹកដីនៃប្រទេសសមាជិកមួយដែលបានធ្វើការនាំចូលទំនិញ

(ជ) **អាជ្ញាធរចេញវិញ្ញាបនបត្រ** មានន័យថា អាជ្ញាធររដ្ឋាភិបាលនៃប្រទេសសមាជិកនាំចេញដែលត្រូវបានចាត់តាំងក្នុងការចេញនូវវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) និងជូនដំណឹងទៅបណ្តាប្រទេសសមាជិកដទៃទៀតស្របទៅតាមឧបសម្ព័ន្ធនេះ

(ឈ) **NSW** (National Single Window) មានន័យថា បញ្ជរតែមួយជាតិ ដូចដែលបានចែងក្នុងមាត្រា៥ (ត) នៃ PLF

(ញ) **ប្រតិវេទន៍ដើមកំណើត** មានន័យថា ការប្រកាសដើមកំណើតទំនិញដែលត្រូវបាននាំចេញដោយអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ដោយអនុលោមតាមវិធានទី១២ (ខ)

(ដ) **PLF (Protocol on the Legal Framework)** មានន័យថា ពិធីសារស្តីពីក្របខណ្ឌច្បាប់ដើម្បីអនុវត្តបញ្ជរតែមួយអាស៊ាន (ASEAN Single Window) ដែលបានបញ្ចប់នៅទីក្រុងហាណូយ ប្រទេសវៀតណាម នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥

(ឋ) **អ្នកផលិត** មានន័យថា រូបវន្តបុគ្គលឬនីតិបុគ្គលដែលអនុវត្តការផលិតដូចបានចែងក្នុងមាត្រា២៥ (ញ) នៃកិច្ចព្រមព្រៀងនេះនៅក្នុងទឹកដីនៃប្រទេសសមាជិក និង

(ឌ) **សំអាងដើមកំណើត (Proof of Origin)** មានន័យថា ឯកសារដែលបានបញ្ជាក់ថាទំនិញដែលបាននាំចេញបានបំពេញតាមបទប្បញ្ញត្តិវិធានដើមកំណើតដូចបានចែងក្នុងជំពូកពានៃកិច្ចព្រមព្រៀងនេះ។

ចិធានទី១ (ក)
សំអាងដើមកំណើត

សំអាងដើមកំណើត អាចមានទម្រង់ដូចជា÷

(ក) វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)

(ខ) វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់ D តាមប្រព័ន្ធអេឡិចត្រូនិក (e-Form D) ឬ

(ត) ប្រតិវេទន៍ដើមកំណើត។

ចិធានទី២
គំរូហត្ថលេខា និងត្រាផ្លូវការរបស់អាជ្ញាធរចេញចិញ្ញាបនបត្រ និងមូលដ្ឋានធិន្លន័យស្វ័យបញ្ជាក់ដើមកំណើតឧទ្ធាំងអាស៊ាន

១. ប្រទេសសមាជិកនីមួយៗត្រូវផ្តល់បញ្ជីឈ្មោះ អាសយដ្ឋាន គំរូហត្ថលេខានិងគំរូត្រាផ្លូវការនៃអាជ្ញាធរចេញវិញ្ញាបនបត្ររៀងៗខ្លួន ជាទម្រង់ច្បាប់ចម្លងរឹងនិងទន់តាមរយៈលេខាធិការដ្ឋានអាស៊ានសម្រាប់ធ្វើការចែកចាយបន្តទៅកាន់ប្រទេសសមាជិកអាស៊ានផ្សេងទៀតក្នុងទម្រង់ច្បាប់ចម្លងទន់។ រាល់មានការផ្លាស់ប្តូរណាមួយនៅក្នុងបញ្ជីដែលបានលើកឡើងត្រូវតែជូនដំណឹងភ្លាមៗតាមរយៈលេខាធិការដ្ឋានអាស៊ានដូចបែបបទខាងលើ។

២. គំរូហត្ថលេខានិងត្រាផ្លូវការនៃអាជ្ញាធរចេញវិញ្ញាបនបត្រដែលត្រូវបានចងក្រងដោយលេខាធិការដ្ឋានអាស៊ានត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ រាល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ណាមួយដែលចេញដោយមន្ត្រីគីមិនរាប់បញ្ចូលក្នុងបញ្ជីដែលយោងទៅកថាខណ្ឌទី១ ហើយនឹងមិនត្រូវបានទទួលយកដោយប្រទេសសមាជិកដែលទទួលនោះទេ។

៣. ទោះបីជាមានចែងក្នុងកថាខណ្ឌទី១និងទី២ក៏ដោយ នៅពេលដែលប្រទេសសមាជិកមួយចេញតែវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់ D តាមប្រព័ន្ធអេឡិចត្រូនិក (e-Form D) ប្រទេសសមាជិកនោះមិនចាំបាច់ផ្តល់នូវបញ្ជីគំរូហត្ថលេខានិងត្រាផ្លូវការនៃអាជ្ញាធរដែលចេញវិញ្ញាបនបត្រនោះទេ។

៤. ភ្លាមៗបន្ទាប់ពីទទួលបានសិទ្ធិក្នុងឋានៈជាអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ប្រទេសសមាជិកនីមួយៗ ត្រូវបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យស្វ័យបញ្ជាក់ដើមកំណើតទូទាំងអាស៊ាន នូវព័ត៌មានដូចខាងក្រោម÷

(ក) ឈ្មោះផ្លូវការ និងអាសយដ្ឋានរបស់ក្រុមហ៊ុន

(ខ) លេខកូដទទួលសិទ្ធិរបស់អ្នកនាំចេញដែលមានការទទួលស្គាល់ (CE)

(គ) កាលបរិច្ឆេទដែលផ្តល់ឱ្យនិងកាលបរិច្ឆេទដែលផុតកំណត់របស់ការផ្តល់សិទ្ធិជាអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ប្រសិនបើមាន

(ឃ) បញ្ជីឈ្មោះផលិតផលដែលបានទទួលសិទ្ធិ រួមមាន ពិពណ៌នាផលិតផលតាមប្រព័ន្ធសុខដុមនីយកម្ម HS ក្នុងទម្រង់ជាលេខ៦ខ្ទង់ ឬនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន AHTN [1] និង

(ង) បញ្ជីហត្ថលេខីដែលទទួលសិទ្ធិនិងគំរូហត្ថលេខាមិនឱ្យលើសពីដប់ (១០) [2] នាក់ក្នុងមួយក្រុមហ៊ុន [3]។

រាល់ការផ្លាស់ប្តូរក្នុងអនុកថាខណ្ឌ (ក) ដល់(ង) ខាងលើត្រូវធ្វើការដាក់បញ្ចូលភ្លាមៗតាមបែបបទដូចខាងលើ។ ការដកឬការព្យួរការទទួលសិទ្ធិក៏ត្រូវធ្វើឡើងតាមបែបបទដូចខាងលើដែរ។

៥. លេខាធិការដ្ឋានអាស៊ានត្រូវថែរក្សាមូលដ្ឋានទិន្នន័យស្វ័យបញ្ជាក់ដើមកំណើតទូទាំងអាស៊ានដែលប្រទេសសមាជិកទាំងអស់អាចចូលប្រើប្រាស់តាមរយៈបណ្តាញអ៊ិនធឺណិត។

៦. រាល់ប្រតិវេទន៍ដើមកំណើតណាដែលបានធ្វើឡើងដោយអ្នកនាំចេញឬហត្ថលេខី ដែលមិនបានបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ ឬសម្រាប់ផលិតផលមួយដែលមិនបានបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ ប្រតិវេទន៍ដើមកំណើតនោះនឹងមិនត្រូវបានទទួលស្គាល់ដោយប្រទេសសមាជិកនោះទេ។

---

[1] ភាពចាំបាច់នៃការរក្សាទុកតម្រូវការនេះ គឺអាស្រ័យលើការពិនិត្យឡើងវិញ បន្ទាប់ពីរយៈពេល២ឆ្នាំ ចាប់ពីថ្ងៃអនុវត្តស្វ័យបញ្ជាក់ដើមកំណើតទូទាំងអាស៊ាន

[2] ភាពចាំបាច់នៃការរក្សាទុកតម្រូវការនេះ គឺអាស្រ័យលើការពិនិត្យឡើងវិញ បន្ទាប់ពីរយៈពេល២ឆ្នាំ ចាប់ពីថ្ងៃអនុវត្តស្វ័យបញ្ជាក់ដើមកំណើតទូទាំងអាស៊ាន

[3] ភាពចាំបាច់នៃការរក្សាទុកតម្រូវការនេះ គឺអាស្រ័យលើការពិនិត្យឡើងវិញ បន្ទាប់ពីរយៈពេល២ឆ្នាំ ចាប់ពីថ្ងៃអនុវត្តស្វ័យបញ្ជាក់ដើមកំណើតទូទាំងអាស៊ាន

មិនានធី៣

ឯកសារយោង

១. ក្នុងគោលបំណងកំណត់ប្រភពដើមទំនិញ អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញឬអាជ្ញាធរមានសមត្ថកិច្ចត្រូវមានសិទ្ធិស្នើសុំឯកសារគាំទ្រនានាជាភ័ស្តុតាងឬធ្វើការចុះត្រួតពិនិត្យដែលចាត់ទុកថាសមស្របដោយអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសជាសមាជិក។

២. ប្រទេសសមាជិកត្រូវបានលើកទឹកចិត្តឱ្យទទួលយកការបញ្ជូនឯកសារយោងនានាជាទម្រង់អេឡិចត្រូនិក (ប្រសិនបើមាន) ដើម្បីអនុវត្តការត្រួតពិនិត្យទាក់ទងនឹងសំអាងដើមកំណើតសមស្របដែលអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសជាសមាជិក។

មិនានធី៤

ការត្រួតពិនិត្យមុនពេលនាំចេញ

១. អ្នកផលិតនិង/ឬអ្នកនាំចេញ ឬអ្នកតំណាងដែលទទួលបានសិទ្ធិ ត្រូវស្នើសុំទៅកាន់អាជ្ញាធរចេញវិញ្ញាបនបត្រ ឬអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការចេញសំអាងដើមកំណើត ឬជាអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ដោយស្នើសុំអោយមានការត្រួតពិនិត្យមុននាំចេញលើដើមកំណើតទំនិញឬលើឋាន:ជាអ្នកនាំចេញដែលមានការទទួលស្គាល់ (CE)ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិក។ លទ្ធផលនៃការត្រួតពិនិត្យនោះត្រូវចាត់ទុកជាភ័ស្តុតាងយោងក្នុងការកំណត់ដើមកំណើតទំនិញនោះដែលត្រូវនាំចេញនៅពេលបន្ទាប់ ដោយអាស្រ័យលើការពិនិត្យឡើងវិញជាប្រចាំ ឬនៅពេលសមស្របណាមួយ។ ការត្រួតពិនិត្យមុនពេលនាំចេញអាចនឹងមិនត្រូវបានអនុវត្តចំពោះទំនិញណាដែលដើមកំណើតអាចត្រូវបានកំណត់យ៉ាងងាយស្រួលដោយលក្ខណៈធម្មជាតិរបស់វា។

២. ចំពោះវត្ថុធាតុដើមណាដែលត្រូវបានផ្គត់ផ្គង់ក្នុងស្រុក ស្វ័យប្រតិវេទន៍របស់អ្នកផលិតចុងក្រោយដែលធ្វើការនាំចេញក្រោមកិច្ចព្រមព្រៀងនេះនឹងត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ដើមកំណើតទំនិញ។

មិនានធី៥

ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)

១. នៅពេលធ្វើបែបបទនាំចេញទំនិញក្រោមប្រព្រឹត្តិកម្មអនុគ្រោះពន្ធ អ្នកនាំចេញឬតំណាងស្របច្បាប់របស់អ្នកនាំចេញត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតជាលាយលក្ខណ៍អក្សរដោយភ្ជាប់មកជាមួយ

នូវឯកសារយោងដែលសមស្របដើម្បីបញ្ជាក់ថាផលិតផលដែលត្រូវនាំចេញមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)។

២. អ្នកនាំចេញដែលមានការទទួលស្គាល់ (CE) អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ជំនួសអោយប្រតិវេទន៍ដើមកំណើតទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

ជំពូកទី៦

ការពិនិត្យពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)

អាជ្ញាធរចេញវិញ្ញាបនបត្រត្រូវធ្វើការពិនិត្យលើពាក្យស្នើសុំឱ្យបានត្រឹមត្រូវនិងអស់ពីសមត្ថភាព ស្របតាមច្បាប់និងបទប្បញ្ញត្តិនានានៃប្រទេសជាសមាជិកដើម្បីធានាថា÷

(ក) ពាក្យស្នើសុំនិងវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ត្រូវបានបំពេញត្រឹមត្រូវនិងចុះហត្ថលេខាដោយអាជ្ញាធរមានសមត្ថកិច្ច។

(ខ) ដើមកំណើតទំនិញគឺស្របទៅនឹងបទប្បញ្ញត្តិនានានៃជំពូកទីពានៃកិច្ចព្រមព្រៀងនេះ។

(គ) សេចក្តីប្រកាសផ្សេងៗទៀតនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតគឺស្របទៅនឹងឯកសារយោងជាភ័ស្តុតាងដែលបានដាក់ជូនភ្ជាប់មកជាមួយ។

(ឃ) ការពិពណ៌នា បរិមាណ និងទម្ងន់នទំនិញ ម៉ាកសញ្ញានិងចំនួនកញ្ចប់ ចំនួននិងប្រភេទកញ្ចប់ដូចបានរៀបរាប់គឺត្រូវស្របទៅនឹងផលិតផលដែលត្រូវនាំចេញ។

(ង) ទំនិញចម្រុះដែលបានប្រកាសនៅលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) តែមួយ ត្រូវបានអនុញ្ញាត ប្រសិនបើមុខទំនិញនីមួយៗមានគុណវុឌ្ឍិគ្រប់គ្រាន់។

ជំពូកទី៧

វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)

១. វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ត្រូវតែជាក្រដាសពណ៌ស ទំហំ ISO A4 ស្របតាមគំរូដែលបង្ហាញក្នុងឧបសម្ព័ន្ធទី៧នៃកិច្ចព្រមព្រៀងនេះ។ វិញ្ញាបនបត្របញ្ជាក់ដើមកំណើតគឺត្រូវធ្វើឡើងជាភាសាអង់គ្លេស។

២. វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ត្រូវមានច្បាប់ដើម (សន្លឹក Original) មួយច្បាប់ និងច្បាប់ចម្លងពីរច្បាប់ (ច្បាប់ចម្លងទី២ និងច្បាប់ចម្លងទី៣)។

៣. វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) នីមួយៗត្រូវមានលេខយោងដាច់ដោយឡែកដែលត្រូវបានផ្តល់ដោយកន្លែងឬការិយាល័យចេញវិញ្ញាបនបត្រនីមួយៗ។

៤. វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) នីមួយៗត្រូវមានហត្ថលេខាដែលទទួលបានសិទ្ធិនិងត្រាផ្លូវការរបស់អាជ្ញាធរចេញវិញ្ញាបនបត្រ។ ហត្ថលេខានិងត្រាបែបនេះអាចនឹងធ្វើឡើងដោយដៃឬជាលក្ខណៈអេឡិចត្រូនិក[4]។

៥. វិញ្ញាបនបត្របញ្ជាក់ដើមកំណើតច្បាប់ដើម (សន្លឹក Original) ត្រូវបញ្ជូនទៅកាន់អ្នកនាំចូលដោយអ្នកនាំចេញដើម្បីដាក់ជូនអាជ្ញាធរគយ ឬអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនៅកំពង់ផែឬកន្លែងនាំចូល។ ច្បាប់ចម្លងទី២ត្រូវរក្សាទុកដោយអាជ្ញាធរចេញវិញ្ញាបនបត្រនៅក្នុងប្រទេសសមាជិកនាំចេញ។ ច្បាប់ចម្លងទី៣ត្រូវរក្សាទុកដោយអ្នកនាំចេញ។

វិធានទី៨

ការប្រកាសលក្ខណៈវិនិច្ឆ័យដើមកំណើតនៅក្នុងវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)

ដើម្បីអនុវត្តន៍បទប្បញ្ញត្តិនានានៃមាត្រា២៦នៃកិច្ចព្រមព្រៀងនេះ វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ដែលចេញដោយប្រទេសសមាជិកនាំចេញចុងក្រោយត្រូវបង្ហាញពីលក្ខណៈវិនិច្ឆ័យដើមកំណើតពាក់ព័ន្ធដែលអាចអនុវត្តបាន។

វិធានទី៩

ប្រព្រឹត្តិកម្មនៃការប្រកាសខុសក្នុងវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)

ការកោសលុបឬសរសេរត្រួតគ្នាមិនត្រូវបានអនុញ្ញាតនៅលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ឡើយ។ ការកែប្រែណាមួយគឺត្រូវបានធ្វើឡើងដោយ÷

(ក) ការឆូតចោលពាក្យខុស និង សរសេរបន្ថែម។ ការកែប្រែរបៀបនេះ ត្រូវមានការយល់ព្រមដោយមន្ត្រីដែលទទួលបានសិទ្ធិចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) និងបញ្ជាក់ដោយអាជ្ញាធរចេញវិញ្ញាបនបត្រ។ ប្រអប់ដែលមិនត្រូវបានប្រើ ត្រូវគូសសញ្ញាខ្វែងដើម្បីចៀសវាងការសរសេរបន្ថែម។

(ខ) ការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ថ្មីជំនួសវិញ្ញាបនបត្របញ្ជាក់ដើមកំណើតដែលបានប្រកាសខុស។

---

[4] ហត្ថលេខានិងត្រាដែលធ្វើឡើងជាអេឡិចត្រូនិកគឺមិនមែនសំដៅទៅលើហត្ថលេខានិងត្រាជាឌីជីថលឡើយ។ ការទទួលយកហត្ថលេខានិងត្រាជាអេឡិចត្រូនិកដោយប្រទេសសមាជិកមួយគឺអាស្រ័យទៅតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិកវៀងៗខ្លួន។

ជំពូកទី១០

ការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)

១. ក្រោមលក្ខខណ្ឌនៃការដាក់ជូនឯកសារតម្រូវទាំងអស់ វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ត្រូវបានចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចេញនៅមុនពេល ឬនៅពេលនាំចេញ ឬចេញភ្លាមៗបន្ទាប់ពីផលិតផលត្រូវបាននាំចេញ ប៉ុន្តែមិនត្រូវលើសពីរយៈពេល៣ថ្ងៃគិតចាប់ពីកាលបរិច្ឆេទប្រកាសដឹកទំនិញចេញ នៅពេលដែលទំនិញនោះត្រូវបានចាត់ទុកថាមានដើមកំណើតក្នុងប្រទេសសមាជិកស្របតាមបទប្បញ្ញត្តិដូចចែងក្នុងជំពូកទី៣នៃកិច្ចព្រមព្រៀងនេះ ។

២. ក្នុងករណីលើកលែងខ្លះ នៅពេលដែលវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) មិនទាន់បានផ្តល់នៅពេលនាំចេញ ឬមិនយឺតជាង៣ថ្ងៃគិតចាប់ពីកាលបរិច្ឆេទប្រកាសដឹកទំនិញចេញអាស្រ័យដោយកំហុសអចេតនា ការលុបចោលឬក៏បណ្តាលមកពីមូលហេតុផ្សេងៗ វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) នោះអាចនឹងត្រូវបានផ្តល់ជាប្រតិសកម្ម ប៉ុន្តែមិនឱ្យយូរជាងមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទដឹកទំនិញចេញ ហើយត្រូវគូសសញ្ញាបញ្ជាក់ក្នុងប្រអប់ "ផ្តល់ជាប្រតិសកម្ម - Issued Retroactively" ។

ជំពូកទី១១

សំអាងដើមកំណើតបន្ត (back-to-back Proof of Origin)

១. អាជ្ញាធរចេញវិញ្ញាបនបត្ររបស់ប្រទេសសមាជិកអន្តរកាលីអាចចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតបន្ត (back-to-back Certificate of Origin) ទម្រង់ D ប្រសិនបើពាក្យស្នើសុំត្រូវបានធ្វើឡើងដោយអ្នកនាំចេញលុះត្រាតែ÷

(ក) សំអាងដើមកំណើតច្បាប់ដើមដែលមានសុពលភាពត្រូវបានបង្ហាញ។ ក្នុងករណីដែលពុំមានសំអាងដើមកំណើតច្បាប់ដើម នោះត្រូវបង្ហាញច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ។

(ខ) វិញ្ញាបនបត្របញ្ជាក់ដើមកំណើតបន្ត (back-to-back Certificate of Origin) ដែលបានចេញរួចគប្បីត្រូវមានព័ត៌មានមួយចំនួនដែលដូចគ្នាទៅនឹងសំអាងដើមកំណើតច្បាប់ដើម។ បន្ថែមពីនេះ រាល់ប្រអប់នៅក្នុងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតបន្ត (back-to-back Certificate of Origin) គប្បីត្រូវបំពេញឱ្យបានត្រឹមត្រូវ។ តម្លៃ FOB របស់ប្រទេសសមាជិកអន្តរកាលីនៅក្នុងប្រអប់ទី៩ក៏នឹងត្រូវបង្ហាញនៅក្នុងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតបន្ត (back-to-back Certificate of Origin) ផងដែរ។

(គ) ចំពោះការនាំចេញជាភាគខ្លះ តម្លៃនាំចេញភាគខ្លះនោះនឹងត្រូវបង្ហាញជំនួសឱ្យតម្លៃសរុបនៃសំអាងដើមកំណើតច្បាប់ដើម។ នៅពេលដែលផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតបន្ត (back-to-back

Certificate of Origin) ដល់អ្នកនាំចេញ ប្រទេសសមាជិកអន្តរការីត្រូវធានាថាបរិមាណសរុបដែលនាំចេញបន្តក្រោមការនាំចេញជាភាគខ្លះនោះនឹងមិនឱ្យលើសបរិមាណសរុបនៃសំអាងដើមកំណើតច្បាប់ដើមពីប្រទេសសមាជិកទី១ឡើយ។

(ឃ) ក្នុងករណីដែលពុំមានព័ត៌មានពេញលេញនិង/ឬក្នុងកាលៈទេសៈដែលគួរឱ្យសង្ស័យ នោះប្រទេសសមាជិកដែលនាំចូលចុងក្រោយអាចស្នើឱ្យផ្តល់ជូននូវសំអាងដើមកំណើតច្បាប់ដើមដល់អាជ្ញាធរគយនៃប្រទេសសមាជិកដែលនាំចូលចុងក្រោយរៀងៗខ្លួន។

(ង) នីតិវិធីផ្សេងផ្តាត់ដែលមានចែងនៅក្នុងវិធានទី១៨និងវិធានទី១៩ក៍អនុវត្តចំពោះ ប្រទេសសមាជិកដែលចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតបន្ត back-to-back Certificate of Origin) ផងដែរ។

(ច) ព័ត៌មាននៅលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតបន្ត (back-to-back Certificate of Origin) រួមមាន កាលបរិច្ឆេទនៃការចេញនិងលេខយោងនៃសំអាងដើមកំណើតច្បាប់ដើម។ ព័ត៌មានទាំងនោះនឹងត្រូវបង្ហាញនៅក្នុងប្រអប់ទី៧នៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតបន្ត (back-to-back Certificate of Origin)។

២. អ្នកនាំចេញដែលមានការទទួលស្គាល់ (CE) មួយ អាចធ្វើប្រតិវេទន៍ដើមកំណើតបន្ត (back-to-back Origin Declaration) លុះត្រាតែ÷

(ក) អ្នកនាំចេញដែលមានការទទួលស្គាល់ (CE) នោះ មានសំអាងដើមកំណើតច្បាប់ដើមដែលមានសុពលភាពពីប្រទេសសមាជិកនាំចេញដំបូង។ ក្នុងករណីដែលពុំមានសំអាងដើមកំណើតច្បាប់ដើមទេ នោះសំអាងដើមកំណើតច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវនឹងត្រូវបានប្រើជំនួស។

(ខ) ប្រតិវេទន៍ដើមកំណើតបន្ត (back-to-back Origin Declaration)ដែលបានចេញគប្បីមានព័ត៌មានមួយចំនួនដែលដូចគ្នាទៅនឹងសំអាងដើមកំណើតច្បាប់ដើម។ តម្លៃ FOBនៃប្រទេសសមាជិកអន្តរការីគប្បីបង្ហាញនៅក្នុងប្រតិវេទន៍ដើមកំណើតបន្ត (back-to-back Origin Declaration)ផងដែរ។

(គ) ចំពោះការនាំចេញជាភាគខ្លះ តម្លៃនាំចេញភាគខ្លះនោះ នឹងត្រូវបង្ហាញជំនួសឱ្យតម្លៃសរុបនៃសំអាងដើមកំណើតច្បាប់ដើម។ អ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ដែលធ្វើប្រតិវេទន៍ដើមកំណើតបន្ត (back-to-back Origin Declaration) នោះនឹងត្រូវធានាថាបរិមាណសរុបដែលនាំចេញបន្តក្រោមការនាំចេញជាភាគខ្លះនោះពុំលើសបរិមាណសរុបនៃសំអាងដើមកំណើតច្បាប់ដើមឡើយ។

(ឃ) នីតិវិធីពិនិត្យផ្សេងផ្តាត់ដែលមានចែងនៅក្នុងវិធានទី១៨និងទី១៩ក៍នឹងត្រូវអនុវត្តចំពោះប្រទេសសមាជិកដែលចេញប្រតិវេទន៍ដើមកំណើតបន្ត (back-to-back Origin Declaration)ផងដែរ។

(ង) អ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ដែលធ្វើប្រតិវេទន៍ដើមកំណើតបន្ត (back-to-back Origin Declaration) នោះគប្បីជាអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ដែលទទួលបានសិទ្ធិអនុញ្ញាតក្នុងការធ្វើប្រតិវេទន៍ដើមកំណើតសម្រាប់ទំនិញដូចគ្នានោះ។

វិធានទី១២

ការបាត់បង់វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)

ក្នុងករណីដែលវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ត្រូវបានចោរលួច បាត់បង់ឬខូច អ្នកនាំចេញអាចដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរចេញវិញ្ញាបនបត្រ ដើម្បីបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើម និងសន្លឹក Triplicate ត្រូវបានធ្វើដោយផ្អែកលើឯកសារនាំចេញ ដែលជាកម្មសិទ្ធិរបស់ពួកគេ ដោយមានភ្ជាប់នូវពាក្យ "CERTIFIED TRUE COPY" ក្នុងប្រអប់ទី១២។ ច្បាប់ចម្លងនេះក៏ត្រូវចុះកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតច្បាប់ដើមផងដែរ។ ការបញ្ជាក់នៅលើច្បាប់ចម្លងនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) នឹងត្រូវផ្តល់ឱ្យក្នុងរយៈពេលមិនលើសពីមួយ (១) ឆ្នាំឡើយ គិតចាប់ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ច្បាប់ដើម។

វិធានទី១២ (ក)

អ្នកនាំចេញដែលមានការទទួលស្គាល់ (Certified Exporter-CE)

១. អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចេញអាចផ្តល់សិទ្ធិដល់អ្នកនាំចេញក្រោមកិច្ចព្រមព្រៀងដោយហៅកាត់ថា "អ្នកនាំចេញដែលមានការទទួលស្គាល់ (CE)" ដើម្បីធ្វើប្រតិវេទន៍ដើមកំណើតពាក់ព័ន្ធនឹងដើមកំណើតទំនិញ។ អ្នកនាំចេញដែលមានបំណងទទួលបានសិទ្ធិនេះត្រូវតែដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរឬក្នុងទម្រង់អេឡិចត្រូនិក ហើយត្រូវតែបំពេញឱ្យបានតាមតម្រូវការរបស់អាជ្ញាធរមានសមត្ថកិច្ចនូវការធានាដែលចាំបាច់ដើម្បីផ្ទៀងផ្ទាត់ដើមកំណើតនៃទំនិញនោះនៅពេលដែលប្រតិវេទន៍ដើមកំណើតមួយត្រូវបានធ្វើឡើង។

២. អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់ឋានៈជាអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) អាស្រ័យលើលក្ខណៈណាដែលអាជ្ញាធរគិតថាសមរម្យរួមទាំងក្នុងករណីណាមួយដូចខាងក្រោម÷

(ក) អ្នកនាំចេញត្រូវបានចុះបញ្ជីត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិកនាំចេញ។

(ខ) អ្នកនាំចេញដែលមានការទទួលស្គាល់ត្រូវតែធានាឱ្យបានថាហត្ថលេខីទទួលបានសិទ្ធិទាំងឡាយដែលទទួលខុសត្រូវចំពោះការធ្វើប្រតិវេទន៍ដើមកំណើត មានចំណេះដឹងនិងយល់អំពីវិធានដើមកំណើតដូចមានចែងក្នុងកិច្ចព្រមព្រៀង។

(គ) អ្នកនាំចេញដែលមានការទទួលស្គាល់គួរតែមានកំរិតបទពិសោធន៍គ្រប់គ្រាន់ក្នុងការនាំចេញ ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិកនាំចេញ។

(ឃ) អ្នកនាំចេញមិនត្រូវមានកំណត់ត្រាក្លែងបន្លំនៃវិធានដើមកំណើតណាមួយឡើយ ដោយអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិកនាំចេញ។

(ង) អ្នកនាំចេញដែលមានការទទួលស្គាល់ត្រូវតែមានការគោរពត្រឹមត្រូវទៅតាមវិធានការនៃការគ្រប់គ្រងហានិភ័យរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចេញ។

(ច) ក្នុងករណីដែលអ្នកនាំចេញគឺជាពាណិជ្ជករ អ្នកនាំចេញនោះត្រូវតែមាន "ប្រតិវេទន៍របស់អ្នកផលិត" ដែលបង្ហាញពីដើមកំណើតនៃផលិតផលក្នុងការធ្វើស្ម័យបញ្ជាក់និងការត្រៀមខ្លួនជាស្រេចរបស់អ្នកផលិតដើម្បីសហការក្នុងការត្រួតពិនិត្យជាលក្ខណៈជាប្រតិសកម្មនិងទស្សនកិច្ចផ្ទៀងផ្ទាត់ ប្រសិនបើចាំបាច់ និង

(ឆ) អ្នកនាំចេញត្រូវតែមានប្រព័ន្ធរក្សាកំណត់ត្រានិងបញ្ជីគណនេយ្យមួយឱ្យបានត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិកនាំចេញ។

៣. ការផ្តល់សិទ្ធិត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់នូវលេខកូដទទួលបានសិទ្ធិដែលត្រូវដាក់បញ្ចូលក្នុងប្រតិវេទន៍ដើមកំណើតទៅអ្នកនាំចេញដែលមានការទទួលស្គាល់ (CE)។ បណ្តាប្រទេសសមាជិកត្រូវបញ្ចូលព័ត៌មានស្តីពីការផ្តល់សិទ្ធិនោះ នៅក្នុងមូលដ្ឋានទិន្នន័យនៃស្ម័យបញ្ជាក់ទូទាំងអាស៊ានជាបន្ទាន់ ដោយអនុលោមតាមវិធានទី២ (ឃ)។

៤. អ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ត្រូវមានកាតព្វកិច្ចដូចតទៅ÷

(ក) អនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះត្រួតពិនិត្យកំណត់ត្រានិងគម្បន្ទានដើម្បីតាមដានការអនុវត្តនិងការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃប្រតិវេទន៍ដែលបានធ្វើឡើង។ កំណត់ត្រានិងគណនីទាំងនោះត្រូវអនុញ្ញាតសម្រាប់ការធ្វើលក្ខណៈវិនិច្ឆ័យនិងការពិនិត្យផ្ទៀងផ្ទាត់ពីដើមកំណើតទំនិញនៅពេលដែលប្រតិវេទន៍ដើមកំណើតមួយត្រូវបានធ្វើឡើងក្នុងរយៈពេលយ៉ាងតិច៣ (បី)ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការចេញប្រតិវេទន៍ ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិកនាំចេញ។

(ខ) ចេញប្រតិវេទន៍ដើមកំណើតចំពោះតែទំនិញដែលអ្នកនាំចេញមានការទទួលស្គាល់ (CE) ទទួលបានសិទ្ធិឱ្យធ្វើប្រតិវេទន៍ដើមកំណើត និងអ្នកនាំចេញមានការទទួលស្គាល់ (CE) មានឯកសារសមស្របទាំងអស់បង្ហាញពីដើមកំណើតនៃទំនិញដែលបានចេញប្រតិវេទន៍នោះ។

(គ) បន្តអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌទី២នៃវិធាននេះ។

(ឃ) សហការក្នុងការត្រួតពិនិត្យជាលក្ខណៈប្រតិសកម្មនិងទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់។

(ង) ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះប្រតិវេទន៍ដើមកំណើតទាំងអស់រួមទាំងការប្រើប្រាស់មិនត្រឹមត្រូវផ្សេងៗនិង

(ច) ជូនដំណឹងជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ចអំពីការផ្លាស់ប្តូរណាដែលទាក់ទងនឹងព័ត៌មានដែលបានដាក់ស្នើតាមវិធានទី២ (ឃ)នៃឧបសម្ព័ន្ធនេះ។

វិធានទី១២ (ខ)

ប្រតិវេទន៍ដើមកំណើត

១. ប្រតិវេទន៍ដើមកំណើតត្រូវមានតម្រូវការទិន្នន័យ ដូចមានបង្ហាញក្នុងឯកសារភ្ជាប់ទី១នៃឧបសម្ព័ន្ធនេះ។

ឯកសារភ្ជាប់ទី១

បញ្ជីនៃតម្រូវការទិន្នន័យ

១.	ព័ត៌មានលម្អិតរបស់ CE	លេខកូដទទួលបានសិទ្ធិរបស់ CE
២.	ការពិពណ៌នាពីទំនិញ	(i) ឈ្មោះផលិតផល (ii) លេខកូដ HS ៦ខ្ទង់ ឬលេខកូដ AHTN (iii) លក្ខណៈវិនិច្ឆ័យដែលទទួលបានដើមកំណើត (iv) ប្រទេសដើមកំណើត (v) តម្លៃ FOB នៅពេលដែលលក្ខណៈវិនិច្ឆ័យសមាសភាគតម្លៃតំបន់ (RVC) ត្រូវបានប្រើប្រាស់ (vi) បរិមាណទំនិញ (vii) ម៉ាកពាណិជ្ជកម្ម ប្រសិនបើមាន និង (viii) ចំពោះករណីប្រតិវេទន៍ដើមកំណើតបន្ត (Back-to-Back Origin Declaration) លេខយោងឯកសារសំអាងដើមកំណើតច្បាប់ដើម កាលបរិច្ឆេទចេញឯកសារ ប្រទេសដើមកំណើតនៃប្រទេសនាំចេញដំបូងព្រមទាំងលេខកូដទទួលបានសិទ្ធិរបស់CEនៃប្រទេសនាំចេញដំបូង ប្រសិនបើមាន
៣.	ការបញ្ជាក់ដើមកំណើតដោយហត្ថលេខីទទួលបានសិទ្ធិ	(i) ការបញ្ជាក់ដើមកំណើតដោយហត្ថលេខីទទួលបានសិទ្ធិរបស់ CE ថា ទំនិញដែលបានបង្ហាញក្នុងប្រតិវេទន៍ដើមកំណើត បានបំពេញរាល់

	តម្រូវការពាក់ព័ន្ធនានានៅក្នុងជំពូកទី៣ នៃកិច្ចព្រមព្រៀងនេះ ដោយផ្អែកលើភ័ស្តុតាងដែលបានផ្តល់ឱ្យ។ (ii) ហត្ថលេខាទទួលបានសិទ្ធិនៅខាងលើឈ្មោះនៃហត្ថលេខីដែលបានបោះត្រាឬបោះពុម្ពចេញ។

២. ប្រតិវេទន៍ដើមកំណើតគួរតែត្រូវបានធ្វើឡើងនៅលើវិក្កយបត្រពាណិជ្ជកម្ម។ ទោះយ៉ាងណា ប្រសិនបើប្រតិវេទន៍ដើមកំណើតពុំអាចធ្វើទៅបាននៅលើវិក្កយបត្រពាណិជ្ជកម្មនៅពេលនាំចេញទេ នោះប្រតិវេទន៍ដើមកំណើតអាចធ្វើឡើងបានតាមរយៈឯកសារពាណិជ្ជកម្មទាំងឡាយ ដូចជា÷ វិក្កយបត្រទូទាត់ (billing statement), ប័ណ្ណបញ្ជារប្រគល់ទំនិញ ឬបញ្ជីវេចខ្ចប់ (delivery order or packing list), ហើយនឹងត្រូវបានទទួលយកនៅពេលនាំចូល ប្រសិនបើមានភ្ជាប់មកជាមួយគ្នាជាមួយនឹងវិក្កយបត្រពាណិជ្ជកម្ម។

៣. ឯកសារដែលមានប្រតិវេទន៍ដើមកំណើតគួរតែពាណិនាអំពីទំនិញឱ្យមានលក្ខណៈលម្អិតគ្រប់គ្រាន់ដើម្បីធ្វើឱ្យទំនិញទាំងនោះអាចសម្គាល់បាន ក្នុងគោលបំណងកំណត់ដើមកំណើត។

៤. ប្រតិវេទន៍ដើមកំណើតត្រូវតែមានឈ្មោះនិងហត្ថលេខាដោយដៃរបស់ហត្ថលេខីទទួលបានសិទ្ធិ។

៥. កាលបរិច្ឆេទនៃឯកសារដែលមានប្រតិវេទន៍ដើមកំណើតត្រូវចាត់ទុកជាកាលបរិច្ឆេទនៃការចេញប្រតិវេទន៍ដើមកំណើត។

៦. លេខយោងនៃឯកសារដែលមានប្រតិវេទន៍ដើមកំណើតត្រូវចាត់ទុកជាលេខយោងនៃប្រតិវេទន៍ដើមកំណើត។

៧. ប្រសិនបើក្នុងករណីដែលពុំមានចន្លោះគ្រប់គ្រាន់នៅក្នុងប្រតិវេទន៍ដើមកំណើតដើម្បីរាយឈ្មោះផលិតផលទាំងអស់ទេ នោះទំព័របន្ថែមដែលមានព័ត៌មានដូចមានចែងក្នុងឯកសារភ្ជាប់ទី១អាចនឹងភ្ជាប់ជាមួយបាន។

[5]ភាពចាំបាច់នៃការរក្សាទុកតម្រូវការនេះ គឺអាស្រ័យលើការពិនិត្យឡើងវិញ បន្ទាប់ពីរយៈពេល៦ឆ្នាំ ចាប់ពីថ្ងៃអនុវត្តស្ងួយបញ្ជាក់ដើមកំណើតទូទាំងអាស៊ាន

វិធានធី១២ (គ)

ការត្រួតពិនិត្យ និងការផ្អៀងផ្នាត់

អាជ្ញាធរមានសមត្ថកិច្ចត្រូវត្រួតពិនិត្យភាពត្រឹមត្រូវនៃការប្រើប្រាស់សិទ្ធិទទួលបាន រួមទាំងការផ្អៀងផ្នាត់អំពីភាពត្រឹមត្រូវនៃប្រតិវេទន៍ដើមកំណើតដែលបានចេញ។ កម្រិតនៃការសម្រេចចិត្តនៃសកម្មភាពបែបនេះគឺអាស្រ័យលើហានិភ័យដែលអាចកើតឡើង។ លើសពីនេះទៀត អាជ្ញាធរមានសមត្ថកិច្ចនឹងមានចំណាត់ការចំពោះសំណើសុំផ្អៀងផ្នាត់ជាប្រតិសកម្មពីអាជ្ញាធរគយរបស់ប្រទេសសមាជិកនាំចូល ស្របតាមវិធានទី១៨។

វិធានធី១២ (ឃ)

ការដកហូតសិទ្ធិ

អាជ្ញាធរមានសមត្ថកិច្ចអាចដកហូតសិទ្ធិក្នុងពេលណាមួយក៏បាន។ ការដកហូតសិទ្ធិនេះត្រូវធ្វើឡើងនៅពេលដែលអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ពុំអាចផ្តល់នូវការធានាដូចមានចែងក្នុងវិធានទី១២ (ក) (១)និងពុំអាចបំពេញលក្ខខណ្ឌដូចមានចែងក្នុងវិធានទី១២ (ក) (២)ឬបំពានលើសិទ្ធិដែលទទួលបាន។ ការដកហូតនេះត្រូវធ្វើឡើងភ្លាម។ នៅក្នុងមូលដ្ឋានទិន្នន័យ ស្វ័យបញ្ជាក់ទូទាំងអាស៊ាន ដោយប្រទេសជាសមាជិកស្របតាមវិធានទី២។

វិធានធី១៣

ការបង្ខាញសំអាងដើមកំណើត

១. សម្រាប់គោលបំណងស្នើសុំអនុវត្តប្រព្រឹត្តិកម្មអនុគ្រោះពន្ធនៅពេលនាំចូល អ្នកនាំចូលត្រូវដាក់ជូនអាជ្ញាធរគយឬអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនៃប្រទេសសមាជិកនាំចូលនូវ÷

(ក) វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) រួមទាំងឯកសារយោងនានាឬ

(ខ) ប្រតិវេទន៍ដើមកំណើតចេញដោយអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) រួមទាំងឯកសារយោងនានា។

២. ក្នុងករណីដែលវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ត្រូវបានបដិសេធដោយអាជ្ញាធរគយឬអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនៃប្រទេសសមាជិកនាំចូល វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)នោះត្រូវគួរសមស្គាល់នៅលើប្រអប់ទី៤ ហើយត្រូវបញ្ជូនច្បាប់ដើមត្រឡប់ទៅអាជ្ញាធរចេញវិញ្ញាបនបត្រតាមពេលវេលាសមរម្យដោយមិនលើសពីរយៈពេល ហុកសិប (៦០)ថ្ងៃ។ អាជ្ញាធរចេញវិញ្ញាបនបត្រត្រូវទទួលបានការជូនដំណឹងពីមូលហេតុនៃការបដិសេធអនុគ្រោះពន្ធ។

៣. ក្នុងករណីដែលប្រតិវេទន៍ដើមកំណើតត្រូវបានបដិសេធដោយអាជ្ញាធរគយនៃប្រទេសសមាជិកនាំចូល ប្រតិវេទន៍ដើមកំណើតនោះត្រូវបញ្ជូនត្រឡប់ទៅអាជ្ញាធរមានសមត្ថកិច្ចតាមពេលវេលាសមរម្យដោយមិនលើសពីរយៈពេលហុកសិប (៦០)ថ្ងៃ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវទទួលបានការជូនដំណឹងពីមូលហេតុនៃការបដិសេធអនុគ្រោះពន្ធ។

៤. ក្នុងករណីដែលសំអាងដើមកំណើតមិនត្រូវបានទទួលយក ដូចមានចែងក្នុងកថាខណ្ឌទី២និងទី៣ខាងលើនៃវិធាននេះ ប្រទេសសមាជិកនាំចូលគួរទទួលយក និងពិចារណាការបំភ្លឺពីអាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ច ហើយធ្វើការវាយតម្លៃជាថ្មីម្តងទៀតលើសំអាងដើមកំណើតនោះ ក្នុងការផ្តល់ឬមិនផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ។ ការបំភ្លឺត្រូវធ្វើឡើងយ៉ាងលម្អិតនិងអស់សេចក្តីក្នុងការឆ្លើយតបទៅនឹងមូលហេតុនៃការបដិសេធអនុគ្រោះពន្ធរបស់ប្រទេសសមាជិកនាំចូល។

ចំណុចទី១៤
សុពលភាពនៃសំអាងដើមកំណើត

ការបង្ហាញនូវសំអាងដើមកំណើតត្រូវស្ថិតក្នុងពេលវេលាកំណត់ដូចខាងក្រោម÷

(ក) សំអាងដើមកំណើតមានសុពលភាពរយៈពេលដប់ពីរ (១២) ខែ ចំពោះបំណងបញ្ជាក់ដើមកំណើត ដោយគិតចាប់ពីកាលបរិច្ឆេទចេញ វិញ្ញាបនបត្រ ឬកាលបរិច្ឆេទចេញប្រតិវេទន៍ដើមកំណើត ហើយត្រូវដាក់ជូនអាជ្ញាធរគយនៃប្រទេសសមាជិកនាំចូលក្នុងរយៈពេលនោះ។

(ខ) នៅពេលដែលសំអាងដើមកំណើតត្រូវបានដាក់ជូនអាជ្ញាធរគយនៃប្រទេសសមាជិកនាំចូលក្រោយពេលផុតសុពលភាព សំអាងដើមកំណើតនោះនៅតែអាចទទួលយកបាននៅពេលដែលការខកខានហួសកាលកំណត់នេះបណ្តាលមកពីមូលហេតុប្រធានសក្តិឬមូលហេតុសមរម្យផ្សេងៗដែលផុតពីការគ្រប់គ្រងរបស់របស់អ្នកនាំចេញ។

(គ) ក្នុងករណីផ្សេងទៀត ការបង្ហាញសំអាងដើមកំណើតយឺតយ៉ាវហួសសុពលភាព អាជ្ញាធរគយនៃប្រទេសនាំចូលអាចនឹងទទួលយកសំអាងដើមកំណើត ប្រសិនបើទំនិញនោះត្រូវបាននាំចូលមុនពេលសំអាងដើមកំណើតផុតសុពលភាព។

ចំណុចទី១៥
ការលើកលែងការតម្រូវឱ្យមានសំអាងដើមកំណើត

ក្នុងករណីដែលទំនិញនាំចូលមានដើមកំណើតពីប្រទេសសមាជិកនាំចេញ និងមានតម្លៃ FOB មិនលើសពី USD 200.00 ការចេញសំអាងដើមកំណើតនឹងត្រូវបានលើកលែង ហើយការប្រើប្រតិវេទន៍បំព្រួញដោយអ្នកនាំចេញ

បញ្ជាក់ថាទំនិញនោះមានដើមកំណើតនៅប្រទេសសមាជិកនាំចេញនឹងត្រូវបានទទួលយក។ ទំនិញផ្ញើតាមប្រៃសណីយ៍ ដែលមានតម្លៃ FOB មិនលើសពី USD 200.00 នឹងត្រូវទទួលបានប្រព្រឹត្តិកម្មស្រដៀងគ្នានេះដែរ។

ជំពូកទី១៦
ប្រព្រឹត្តិកម្មចំពោះគោលមិនប្រក្រតីតិចតួច

១. ប្រសិនបើដើមកំណើតក្នុងអាស៊ានរបស់ទំនិញមិនស្ថិតក្នុងការសង្ស័យទេ ការរកឃើញនូវភាពមិនប្រក្រតីតិចតួចដូចជា កំហុសក្នុងការបោះពុម្ពរវាងអំណះអំណាងនៅក្នុងសំអាងដើមកំណើត និងឯកសារយោងដែលបានដាក់ជូនអាជ្ញាធរគយប្រទេសសមាជិកនាំចូលសម្រាប់គោលបំណងបំពេញបែបបទនាំចូលទំនិញមិនត្រូវធ្វើឱ្យមោឃៈឯកសារទេ ឱ្យតែឯកសារនោះត្រូវជាមួយទំនិញជាក់ស្តែងពិតមែន។

២. នៅពេលប្រទេសសមាជិកនាំចេញ និងប្រទេសសមាជិកនាំចូលមានចំណាត់ថ្នាក់ផ្សេងគ្នាលើទំនិញដែលជាកម្មវត្ថុនៃការអនុគ្រោះពន្ធ ទំនិញនោះត្រូវបានអនុញ្ញាតឱ្យបញ្ចេញទំនិញពីគយតាមអត្រា MFN ឬអត្រាអនុគ្រោះណាមួយដែលខ្ពស់ជាង ឱ្យតែមានអនុលោមភាពតាមវិធានដើមកំណើតទំនិញដោយមិនមានការជាកពិន័យឬបន្ទុកចំណាយផ្សេងទៀត តាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានារបស់ប្រទេសសមាជិកនាំចូល។ នៅពេលវិវាទចំណាត់ថ្នាក់ត្រូវបានដោះស្រាយ អត្រាត្រឹមត្រូវនឹងត្រូវអនុវត្ត ចំណែកពន្ធនិងអាករដែលបានបង់លើសត្រូវបង្វិលសងវិញភ្លាមបើអាច យោងតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិកនាំចូល។

៣. ចំពោះទំនិញច្រើនមុខប្រកាសក្នុងសំអាងដើមកំណើតតែមួយ បញ្ហាដែលកើតមានឡើងចំពោះទំនិញណាមួយមិនត្រូវប៉ះពាល់ ឬពន្យារនូវការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ និងការបញ្ចេញទំនិញពីគយនៃទំនិញផ្សេងទៀតដែលមានក្នុងសំអាងដើមកំណើតនោះឡើយ។ វិធានទី១៨(គ) អាចត្រូវយកមកអនុវត្តចំពោះមុខទំនិញដែលមានបញ្ហានេះ។

ជំពូកទី១៧
លក្ខខណ្ឌរក្សាទុកឯកសារ

១. ចំពោះគោលបំណងនៃដំណើរការពិនិត្យផ្ទៀងផ្ទាត់ អនុលោមទៅតាមវិធានទី១៨និងទី១៩ និងបទប្បញ្ញត្តិនានានៃប្រទេសសមាជិកនាំចេញ អ្នកផលិតនិង/ឬអ្នកនាំចេញដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) និងអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ដែលធ្វើប្រតិវេទន៍ដើមកំណើតត្រូវរក្សាឯកសារយោងនានាក្នុងរយៈពេលមិនតិចជាងបី (៣) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញសំអាងដើមកំណើត ។

២. ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) និងឯកសារពាក់ព័ន្ធត្រូវបានរក្សាទុកដោយអាជ្ញាធរចេញវិញ្ញាបនបត្រក្នុងរយៈពេលមិនតិចជាងបី (៣) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D)។

៣. ពាក្យស្នើសុំជាអ្នកនាំចេញដែលមានការទទួលស្គាល់ (CE) និងឯកសារពាក់ព័ន្ធនឹងសំណើទាំងអស់ ត្រូវបានរក្សាទុកដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេលមិនតិចជាងបី (៣) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការផុតសុពលភាព ឬការដកហូតនូវការផ្តល់សិទ្ធិ។

៤. ព័ត៌មានទាក់ទងទៅនឹងសុពលភាពវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) និងភាពត្រឹមត្រូវនៃប្រតិវេទន៍ដើមកំណើតត្រូវបានផ្តល់តបតាមសំណើរបស់ប្រទេសសមាជិកនាំចូលតាមរយៈមន្ត្រីមានសមត្ថកិច្ចក្នុងការចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) និងបញ្ជាក់ដោយអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចេញ។

៥. រាល់ព័ត៌មានដែលបានទាក់ទងគ្នារវាងប្រទេសសមាជិកពាក់ព័ន្ធត្រូវរក្សាជាការសម្ងាត់ និងសម្រាប់តែគោលបំណងផ្ទៀងផ្ទាត់សុពលភាពនៃសំអាងដើមកំណើតប៉ុណ្ណោះ។

ចំណាន៦១៨
ការត្រួតពិនិត្យជាប្រតិសកម្ម

ប្រទេសសមាជិកនាំចូលអាចស្នើទៅអាជ្ញាធរចេញវិញ្ញាបនបត្រ ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចេញ ដើម្បីធ្វើការត្រួតពិនិត្យជាប្រតិសកម្មដោយចោះ។ និង/ឬនៅពេលមានចម្ងល់សមស្របអំពីភាពស្របច្បាប់នៃឯកសារ ឬក៏ភាពត្រឹមត្រូវនៃព័ត៌មានពាក់ព័ន្ធនឹងដើមកំណើតពិតនៃទំនិញដែលមានការសង្ស័យ ឬផ្នែកខ្លះរបស់ទំនិញនោះ។ ផ្អែកតាមសំណើនេះ អាជ្ញាធរចេញវិញ្ញាបនបត្រ ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចេញ ត្រូវធ្វើការត្រួតពិនិត្យជាប្រតិសកម្មលើរបាយការណ៍នៃថ្លៃទំនិញរបស់អ្នកផលិតឬអ្នកនាំចេញក្នុងរយៈពេលប្រាំមួយ (៦) ខែ ចាប់ពីកាលបរិច្ឆេទដែលទំនិញបាននាំចេញ ផ្អែកទៅតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម÷

(ក) ប្រសិនបើមិនមានការស្នើត្រួតពិនិត្យជាប្រតិសកម្មដោយចោះ។ ទេនោះ សំណើត្រួតពិនិត្យជាប្រតិសកម្មត្រូវធ្វើឡើងដោយមានភ្ជាប់ជាមួយនូវសំអាងដើមកំណើតពាក់ព័ន្ធ ព្រមទាំងត្រូវបញ្ជាក់ពីមូលហេតុ និងព័ត៌មានបន្ថែមនានាដែលបញ្ជាក់ថាភាពមិនប្រក្រតី ដែលមាននៅក្នុងសំអាងដើមកំណើតអាចមិនត្រឹមត្រូវ។

(ខ) អាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ចដែលបានទទួលនូវសំណើត្រួតពិនិត្យជាប្រតិសកម្មត្រូវឆ្លើយតបទៅនឹងសំណើភ្លាម។ ក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើត្រួតពិនិត្យជាប្រតិសកម្ម។

(គ) អាជ្ញាធរគយនៃប្រទេសសមាជិកនាំចូលអាចព្យួរការអនុវត្តបទប្បញ្ញត្តិស្តីពីប្រព្រឹត្តិកម្មអនុគ្រោះពន្ធក្នុងអំឡុងពេលរង់ចាំលទ្ធផលពិនិត្យផ្ទៀងផ្ទាត់។ ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរគយអាចធ្វើការបញ្ចេញទំនិញ ដោយផ្អែកលើវិធានការរដ្ឋបាលនានាដែលចាំបាច់ ឱ្យតែទំនិញនោះមិនមែនជាកម្មវត្ថុនៃការហាមឃាត់ឬជាប់កម្រិតកំណត់និងមិនមានការសង្ស័យថាមានល្មើស។ និង

(ឃ) អាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ជូនលទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់ទៅប្រទេសសមាជិកនាំចូល ដើម្បីកំណត់ថាតើទំនិញនោះទទួលបានដើមកំណើតឬទេ។ ដំណើរការទាំងមូលនៃការត្រួតពិនិត្យជាប្រតិសកម្មនេះ រួមទាំងការផ្តល់ប្រវែទន៍ទៅអាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចេញអំពីលទ្ធផលនៃការកំណត់ថាតើទំនិញនោះទទួលបានដើមកំណើតឬទេ ត្រូវបញ្ចប់ក្នុងរយៈពេលមួយរយប៉ែតសិប (១៨០) ថ្ងៃ។ ខណៈពេលដែលរង់ចាំលទ្ធផលនៃការត្រួតពិនិត្យជាប្រតិសកម្មនេះ កថាខណ្ឌ (គ) នឹងត្រូវយកមកអនុវត្ត។

ចំណុចទី១៩
ទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់

១. ប្រសិនបើប្រទេសសមាជិកនាំចូលមិនពេញចិត្តពីលទ្ធផលនៃការត្រួតពិនិត្យជាប្រតិសកម្មនោះទេ ក្នុងករណីលើកលែង អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចូលអាចស្នើធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់នៅប្រទេសសមាជិកនាំចេញ។

២. មុនពេលធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ ប្រទេសសមាជិកនាំចូលត្រូវចេញប្រវែទន៍ជាលាយលក្ខណ៍អក្សរពីគោលបំណងនៃការធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ទៅកាន់÷

(ក) អ្នកនាំចេញឬអ្នកផលិតអំពីទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ដែលត្រូវធ្វើឡើងនៅគម្បដ្ឋានរបស់គាត់។

(ខ) អាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិកនាំចេញ អំពីទីកន្លែងដែលត្រូវធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់។

(គ) អាជ្ញាធរគយឬអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនៃប្រទេសសមាជិកអំពីទីកន្លែងដែលត្រូវធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់។

(ឃ) អ្នកនាំចូលទំនិញដែលជាកម្មវត្ថុនៃការធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់។

៣. ប្រវែទន៍ជាលាយលក្ខណ៍អក្សរដែលមានចែងក្នុងកថាខណ្ឌទី២ត្រូវធ្វើឡើងដោយមានលក្ខណៈលម្អិតច្បាស់លាស់តាមដែលអាចធ្វើទៅបាន ដោយរួមមាន÷

(ក) ឈ្មោះនិងអាសយដ្ឋាននៃអាជ្ញាធរគយ ឬអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធដែលចេញប្រវែទន៍។

(ខ) ឈ្មោះនិងអាសយដ្ឋានអ្នកនាំចេញ ឬអ្នកផលិតដែលត្រូវធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ដល់គម្បដ្ឋានរបស់គាត់។

(គ) កាលបរិច្ឆេទស្នើសុំសម្រាប់ការធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់។

(ឃ) វិសាលភាពនៃសំណើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ រួមទាំងការបរិយាយមុខទំនិញដែលជាកម្មវត្ថុនៃទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់។ និង

(ង) ឈ្មោះ និងតួនាទីមន្ត្រីដែលចាត់តាំងឱ្យដឹកនាំធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់។

៤. ប្រទេសសមាជិកនាំចូលត្រូវទទួលនូវការអនុញ្ញាតជាលាយលក្ខណ៍អក្សរយល់ព្រមរបស់អ្នកនាំចេញឬអ្នកផលិតពីគម្រោងដែលត្រូវធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ ដូចដែលមានចែងក្នុងកថាខណ្ឌទី២ មុននឹងចុះទៅពិនិត្យផ្ទៀងផ្ទាត់។

៥. ប្រទេសសមាជិកនាំចូលអាចបដិសេធផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះចំពោះទំនិញជាកម្មវត្ថុដែលនឹងត្រូវចុះទៅទស្សនកិច្ច ពិនិត្យផ្ទៀងផ្ទាត់នៅពេលដែលពុំទទួលបាននូវការអនុញ្ញាតជាលាយលក្ខណ៍អក្សរយល់ព្រមរបស់អ្នកនាំចេញ ឬអ្នកផលិតក្នុងរយៈពេលសាមសិប (៣០) ថ្ងៃគិត ចាប់ពីកាលបរិច្ឆេទចេញប្រវែទន៍របស់ខ្លួនអនុលោមតាមកថាខណ្ឌទី២នោះ។

៦. អាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ចដែលទទួលបាននូវប្រវែទន៍ អាចពន្យារទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់បាន និងជូនដំណឹងទៅកាន់ប្រទេសសមាជិកនាំចូលអំពីបំណងនេះ។ យ៉ាងណាមិញ ក្រៅពីការពន្យារពេលនានា ទស្សនកិច្ចត្រួតពិនិត្យផ្ទៀងផ្ទាត់នឹងត្រូវធ្វើឡើងក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលទទួលបានប្រវែទន៍នៃប្រទេសសមាជិកនាំចូល ឬរយៈពេលវែងជាងនេះដូចដែលប្រទេសសមាជិកពាក់ព័ន្ធបានព្រមព្រៀង។

៧. ប្រទេសសមាជិកដែលធ្វើទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ អាចផ្តល់ដល់អ្នកនាំចេញ ឬអ្នកផលិត និងដល់អាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ច នូវប្រវែទន៍ជាលាយលក្ខណ៍អក្សរបញ្ជាក់ថាតើទំនិញរបស់គាត់ទទួលបានដើមកំណើតឬទេ។

៨. ការព្យួរនូវប្រព្រឹត្តិកម្មអនុគ្រោះពន្ធត្រូវធ្វើឱ្យដូចនឹងការផ្តល់ប្រវែទន៍ជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងកថាខណ្ឌទី៧ បញ្ជាក់ថាទំនិញនោះ មានគុណវុឌ្ឍិជាទំនិញដើមកំណើត។

៩. អ្នកនាំចេញឬអ្នកផលិតត្រូវបានអនុញ្ញាតក្នុងការផ្តល់ការអត្ថាធិប្បាយឬព័ត៌មានបន្ថែមចំពោះភាពត្រឹមត្រូវនៃទំនិញក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីការបរិច្ឆេទទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ប្រសិនបើរកឃើញថាទំនិញមិនទទួលបានដើមកំណើតទេ ការធ្វើប្រវែទន៍ជាលាយលក្ខណ៍អក្សរចុងក្រោយនឹងត្រូវផ្តល់ជូនទៅអាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលការអត្ថាធិប្បាយ ឬព័ត៌មានបន្ថែមពីអ្នកនាំចេញឬអ្នកផលិត។

១០. ដំណើរការនៃទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ រួមមានការចុះពិនិត្យជាក់ស្តែង និងការកំណត់ដើមកំណើតរបស់ទំនិញព្រមទាំងលទ្ធផលដែលជូនដំណឹងដល់អាជ្ញាធរចេញវិញ្ញាបនបត្រឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តក្នុងរយៈពេលមួយរយប៉ែតសិប (១៨០) ថ្ងៃជាអតិបរមា។ ក្នុងពេលរង់ចាំលទ្ធផលនៃទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ វិធានទី១៨ (គ) នឹងត្រូវយកមកអនុវត្ត។

វិធានទី២០

ការរក្សាការសម្ងាត់

យោងតាមច្បាប់និងបទប្បញ្ញត្តិប្រទេសសមាជិករៀងៗខ្លួន ប្រទេសសមាជិកត្រូវរក្សាការសម្ងាត់នៃព័ត៌មានធុរកិច្ចដែលប្រមូលបានអំឡុងពេលពិនិត្យផ្ទៀងផ្ទាត់ ដោយអនុលោមតាមវិធានទី១៨ និងទី១៩ និងត្រូវការពារការលាតត្រដាងនូវព័ត៌មានដែលអាចបណ្តាលឱ្យប៉ះពាល់ដល់ស្ថានភាពប្រកួតប្រជែងរបស់បុគ្គលដែលបានផ្តល់ព័ត៌មាន។ ព័ត៌មានសម្ងាត់នេះអាចត្រូវបានបង្ហាញដល់អាជ្ញាធរដែលទទួលខុសត្រូវ សម្រាប់កិច្ចការរដ្ឋបាល និងពង្រឹងការអនុវត្តការកំណត់ដើមកំណើតទំនិញតែប៉ុណ្ណោះ។

វិធានទី២១

ការបង្ហាញឯកសារសម្រាប់ការអនុវត្តមាត្រា៣២ (២) (ខ)

(ការដឹកជញ្ជូនដោយផ្ទាល់)

ក្នុងគោលបំណងនៃការអនុវត្តមាត្រា៣២ (២) (ខ)នៃកិច្ចព្រមព្រៀងនេះ នៅពេលដែលការដឹកជញ្ជូនប្រព្រឹត្តឡើងដោយឆ្លងកាត់ដែនដីនៃប្រទេសមិនមែនជាសមាជិកអាស៊ានមួយឬច្រើន ឯកសារខាងក្រោមជាតម្រូវការចាំបាច់របស់អាជ្ញាធររបស់ប្រទេសសមាជិកនាំចូល÷

(ក) អញ្ជាត្តិប័ណ្ណដឹកជញ្ជូននៃប្រទេសសមាជិកនាំចេញ។

(ខ) វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) ដែលចេញដោយអាជ្ញាធរពាក់ព័ន្ធនៃប្រទេសសមាជិកនាំចេញឬ ប្រតិវេទន៍ដើមកំណើតដែលប្រកាសដោយអ្នកនាំចេញទទួលបានការអនុញ្ញាតក្នុងប្រទេសសមាជិកនាំចេញ។

(គ) ច្បាប់ចម្លងនៃ វិក្កយបត្រពាណិជ្ជកម្មច្បាប់ដើមនៃទំនិញ។ និង

(ឃ) ឯកសារយោងនានាដែលជាតម្រូវការ ផ្អែកតាមការតម្រូវនៃមាត្រា៣២ (២) (ខ) កថាខណ្ឌ (i) (ii) និង (iii)នៃកិច្ចព្រមព្រៀងនេះ។

វិធានទី២២
ទំនិញពិព័រណ៍

១. ទំនិញដែលបានបញ្ជូនពីប្រទេសសមាជិកនាំចេញសម្រាប់ធ្វើការតាំងពិព័រណ៍ក្នុងប្រទេសសមាជិកដទៃទៀត និងដាក់លក់អំឡុងពេល ឬក្រោយពេលតាំងពិព័រណ៍ ត្រូវបានផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ស្របតាមកិច្ចព្រមព្រៀងនេះ ក្នុងករណីដែលទំនិញនោះបំពេញតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកពានៃកិច្ចព្រមព្រៀងនេះ និងស្របទៅតាមបទប្បញ្ញត្តិនានានៃប្រទេសសមាជិកនាំចូល ដូចខាងក្រោម÷

(ក) អ្នកនាំចេញបានបញ្ជូនទំនិញទាំងនោះពីដែនដីនៃប្រទេសសមាជិកនាំចេញទៅកាន់ប្រទេសសមាជិកនាំចូល ដែលជាកន្លែងតាំងពិព័រណ៍ប្រារព្ធឡើង ហើយបានដាក់តាំងពិព័រណ៍នៅទីនោះ។

(ខ) អ្នកនាំចេញបានលក់ទំនិញឬបានផ្ទេរទំនិញទាំងនោះទៅឱ្យអ្នកទទួលបញ្ជើក្នុងប្រទេសសមាជិកនាំចូល។

(គ) ទំនិញត្រូវបានដឹកជញ្ជូនក្នុងអំឡុងពេល ឬភ្លាមៗក្រោយពេលតាំងពិព័រណ៍នៅក្នុងប្រទេសសមាជិកនាំចូល ក្នុងស្ថានភាពដែលទំនិញនោះត្រូវបានបញ្ជូនមកសម្រាប់គោលបំណងតាំងពិព័រណ៍។

២. ដើម្បីអនុវត្តកថាខណ្ឌទី១ វិញ្ញាបនបត្របញ្ជាក់ដើមកំណើត(ទម្រង់D) ឬប្រតិវេទន៍ដើមកំណើត ក្នុងករណីអ្នកនាំចេញទទួលបានការអនុញ្ញាត នឹងត្រូវបានផ្តល់ដល់អាជ្ញាធរពាក់ព័ន្ធនៃប្រទេសសមាជិកនាំចូល។ ឈ្មោះនិងអាសយដ្ឋាននៃកន្លែងតាំងពិព័រណ៍នឹងត្រូវបង្ហាញ។ អាជ្ញាធរនានានៃប្រទេសប្រារព្ធពិធីតាំងពិព័រណ៍អាចនឹងផ្តល់នូវឯកសារយោងជាភ័ស្ពុតាង ដូចដែលបានបរិយាយក្នុងវិធានទី២១ (ឃ) ចំពោះអត្តសញ្ញាណនៃផលិតផលនិងលក្ខខណ្ឌនៃទំនិញដែលត្រូវយកមកធ្វើការតាំងពិព័រណ៍។

៣. កថាខណ្ឌទី១ ត្រូវបានអនុវត្តចំពោះការតាំងពិព័រណ៍ពាណិជ្ជកម្ម ផលិតផលកសិកម្មឬសិប្បកម្ម ឬក៏ការដាក់តាំងបង្ហាញស្រដៀងគ្នា ឬការដាក់តាំងបង្ហាញក្នុងហាង ឬក្នុងអគារពាណិជ្ជកម្ម ក្នុងទិដ្ឋភាពនៃការដាក់លក់ទំនិញបរទេសនិងក្នុងលក្ខខណ្ឌដែលទំនិញស្ថិតក្រោមការគ្រប់គ្រងរបស់គយអំឡុងពេលតាំងពិព័រណ៍។

វិធានទី២៣
ការចេញវិក្កយបត្រដោយប្រទេសទីបី

១. អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនៃប្រទេសសមាជិកនាំចូលត្រូវទទួលយកសំអាងដើមកំណើត ក្នុងករណីដែលវិក្កយបត្រលក់ទំនិញចេញដោយក្រុមហ៊ុនមានទីតាំងក្នុងប្រទេសទីបី ឬចេញដោយអ្នកនាំចេញក្នុងប្រទេសសមាជិកអាស៊ានក្នុងនាមជាក្រុមហ៊ុននោះនៅពេលដែលទំនិញបំពេញតាមលក្ខខណ្ឌនៃជំពូកទីពានៃកិច្ចព្រមព្រៀងនេះ។

២ អ្នកនាំចេញត្រូវបង្ហាញ "third country invoicing" និងព័ត៌មានមួយចំនួន ដូចជា ឈ្មោះក្រុមហ៊ុន និងប្រទេសដែលចេញវិក្កយបត្រនៅក្នុងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (ទម្រង់ D)។

៣ ក្នុងករណីដែលវិក្កយបត្រលក់ត្រូវបានចេញដោយក្រុមហ៊ុនដែលមានទីតាំងនៅក្នុងប្រទេសទីបី ឬដោយអ្នកនាំចេញក្នុងប្រទេសសមាជិកអាស៊ានក្នុងនាមជាក្រុមហ៊ុននោះ អ្នកនាំចេញដែលមានការទទួលស្គាល់ (CE) អាចចេញប្រតិវេទន៍ដើមកំណើតទំនិញនៅលើវិក្កយបត្រទូទាត់ ប័ណ្ណបញ្ជារប្រគល់ទំនិញ ឬបញ្ជីវេចខ្ចប់បាន។

វិធានទី២៤
សកម្មភាពប្រឆាំងអំពើក្លែងបន្លំ

១ នៅពេលមានការសង្ស័យថាមានសកម្មភាពក្លែងបន្លំទាក់ទងនឹងសំអាងដើមកំណើតកើតឡើង អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធត្រូវសហការគ្នាទៅវិញទៅមករវាងប្រទេសសមាជិកនីមួយៗ ដើម្បីប្រឆាំងសកម្មភាព ឬបុគ្គលប្រព្រឹត្តបទល្មើសនោះ។

២ ប្រទេសសមាជិកនីមួយៗ ត្រូវដាក់ទណ្ឌកម្មផ្លូវច្បាប់ ចំពោះរាល់សកម្មភាពក្លែងបន្លំទាក់ទងទៅនឹងសំអាងដើមកំណើត។

វិធានទី២៥
តម្លៃ FOB

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ក្រៅពីវិធានទី១១ (ខ) សំអាងដើមកំណើត និងសំអាងដើមកំណើតបន្ត (back-to-back Proof of Origin) ត្រូវតែបង្ហាញតម្លៃ FOB តាមការតម្រូវរបស់ប្រទេសជាសមាជិក ដូចមានចែងក្នុងកថាខណ្ឌពាក់ព័ន្ធនឹងតម្លៃ FOB នៅលើកំណត់សម្គាល់នៅទំព័រខាងខ្នង (Overleaf Notes) នៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (ទម្រង់ D) ក្នុងករណីដែលតម្លៃសមាសភាគក្នុងតំបន់បានគណនាដោយប្រើរូបមន្តដែលមានចែងក្នុងមាត្រា២៩ នៃកិច្ចព្រមព្រៀងនេះ គឺត្រូវបានអនុវត្តក្នុងការកំណត់ដើមកំណើត។

វិធានទី២៦
សមតាវនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់ក្រដាស និងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់ D តាមប្រព័ន្ធអេឡិចត្រូនិក (e-Form D)

១. វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ទម្រង់ D) តាមប្រព័ន្ធអេឡិចត្រូនិក អាចស្នើសុំផ្តល់ជូន និងទទួលយកជំនួសឱ្យវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់ក្រដាស ដោយមានប្រសិទ្ធភាពគតិយុត្តស្មើគ្នា។

២. វិធានទី២៧ដល់វិធានទី៣១ ត្រូវអនុវត្តចំពោះវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់D តាមប្រព័ន្ធអេឡិចត្រូនិក (e-Form D)។ លើកលែងតែមានការបញ្ជាក់ផ្សេងៗ ចាប់ពីវិធានទី២៧ រហូតដល់វិធានទី៣១ ចាប់ពីវិធាន

ទី១ រហូតដល់វិធានទី៦ វិធានទី៨ វិធានទី១០ វិធានទី១១ ចាប់ពីវិធានទី១៤ រហូតដល់វិធានទី១៦ និងចាប់ពីវិធានទី១៨ រហូតដល់វិធានទី២៥ ក៏នឹងត្រូវអនុវត្តដំណើរការនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់ D អេឡិចត្រូនិក (e-Form D)នេះដែរ។

វិធានទី២៧

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់ D តាមប្រព័ន្ធអេឡិចត្រូនិក (e-Form D)

(a) generate an electronic Customs Response indicating the rejection status with reasons for the rejection, including, as appropriate, the reason for denial of tariff preference, in accordance with the ATIGA e-Form D Process Specification and Message Implementation Guideline. The electronic Customs Response, if generated, shall be transmitted electronically via the ASW to the Issuing Authority in the exporting Member State within a reasonable period not exceeding sixty (60) days from the date of receipt of the Electronic Certificate of Origin (e-Form D); or

(b) in cases where the procedure in paragraph 3(a) is not available, the customs authority of the importing Member State may notify the Issuing Authority of the exporting Member State in writing of the grounds for the denial of tariff preference together with the reference number of the Electronic Certificate of Origin (e-Form D), within a reasonable period not exceeding sixty (60) days.

4. In the case where an Electronic Certificate of Origin (e-Form D) is not accepted, as stated in the preceding paragraph, the importing Member State should accept and consider the clarifications made by the Issuing Authority and assess again whether or not the e-Form D application can be accepted for the granting of the preferential treatment. The clarifications should be detailed and exhaustive in addressing the grounds of denial of preference raised by the importing Member State.

Rule 31
Electronic Archiving and Data Retention

1. For the purposes of the verification process pursuant to Rules 18 and 19, the producer and/or exporter applying for the issuance of an Electronic Certificate of Origin (e-Form D) shall, subject to the laws and regulations of the exporting Member State, provide for the storage of supporting records for application for an Electronic Certificate of Origin (e-Form D) for not less than three (3) years from the date of issuance of the Electronic Certificate of Origin (e-Form D).

2. The application for an Electronic Certificate of Origin (e-Form D) and all documents related to such application shall be retained by the Issuing Authority for not less than three (3) years from the date of issuance of the Electronic Certificate of Origin (e-Form D).

3. Information relating to the validity of the Electronic Certificate of Origin (e-Form D) shall be furnished upon request of the importing Member State, by an authorised official of the Issuing Authority.

4. Any information communicated between the Member States concerned shall be treated as confidential and shall be used for the purpose of Electronic Certificate of Origin (e-Form D) validation only.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៥៨...សប្រទ

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជរដ្ឋាភិបាលកម្ពុជា

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម **ទឿ ទិស្សុត** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជារដ្ឋមន្ត្រីក្រុមប្រឹក្សាអាហ្វតាអាស៊ានសម្រាប់កម្ពុជា ដើម្បីចុះហត្ថលេខា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លើពិធីសារទី១ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (First Protocol to Amend the ASEAN Trade in Goods Agreement)។

ក្នុងករណីឯកឧត្តម **ទឿ ទិស្សុត** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

អាស្រ័យហេតុនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចដែលច្បាប់បានប្រគល់ជូន បានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ។

ថ្ងៃសន្ទាវសកើតខែ សស្ទូវ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែតុលា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

N. 58 DFP

Phnom Penh, 16 October, 2018

DELEGATION OF FULL POWER

- Having seen the constitution of the Kingdom of Cambodia;
- Having seen the Royal Decree No. NS/RKT/0918/925 dated 06 September 2018 on the composition of the Royal Government of Cambodia;
- Having seen the Royal Decree No. NS/RKM/0618/012 dated 28 June 2018 on the Organization and Functioning of the Council of Ministers;
- Referring to the request of the Ministry of Economy and Finance

THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith full power to **H.E. VONGSEY VISOTH,** Secretary of State, Ministry of Economy and Finance, and AFTA Council Minister for Cambodia, to sign, on behalf of the Royal Government of Cambodia, First Protocol to Amend the ASEAN Trade in Goods Agreement.

This power includes the power of delegation.

In witness whereof, the undersigned, Samdech Akka Moha Sena Padei Techo **HUN SEN**, Prime Minister of the Kingdom of Cambodia, with full power duly entrusted to him, has signed this delegation of full power.

PRIME MINISTER

Samdech Akka Moha Sena Padei Techo HUN SEN

ព្រះរាជក្រឹត្យ

នស/រកត/០៤២០/៤៣៩ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោតាស កម្ពុជ៦ករាជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្ទាប់

មាត្រា១.- ដំឡើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ៖

ក-ថ្នាក់ឲត្តមសេនីយ៍ឆោ

១-ឧត្តមសេនីយ៍ត្រី **សរ ខន្តី**	អត្តលេខ ៦៦៨២៧
២-ឧត្តមសេនីយ៍ត្រី **ហ៊ាន ពុត្រា**	អត្តលេខ ៧៧៧០៣
៣-ឧត្តមសេនីយ៍ត្រី **ឆ្លុង មិថុនា**	អត្តលេខ ៧៧៨៥៧។

ខ-ថ្នាក់ឲត្តមសេនីយ៍ត្រី

១-លោកវរសេនីយ៍ឯក **អាន កក្កជា**	អត្តលេខ ៧០៨៤៥
២-លោកវរសេនីយ៍ឯក **ណ៊ី សុគន្ធីរ៉ា**	អត្តលេខ ៧៨១៨៤។

មាត្រា២.- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០២០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បន្ទាប់

ប្រមុខរដ្ឋស្តីទី

ឆ.ស.

ចាវស.២០០៤.៤៥៣

សម្តេចវិបុលសេនាតក្តី សាយ ឈុំ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ខបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៤២០/៤៤០ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខែតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ ដំឡើងឋានន្តរស័ក្តិជូនដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

ក- ថ្នាក់ឧត្តមសេនីយ៍ទោ

១-	ឧត្តមសេនីយ៍ត្រី	**ប៉ែន ផល្លា**	អត្តលេខ	៤៥៧៣៨
២-	ឧត្តមសេនីយ៍ត្រី	**សែន ពិសិដ្ឋជានីតា**	អត្តលេខ	៥៦៣៥៣
៣-	ឧត្តមសេនីយ៍ត្រី	**សក់ កែវថ្លាវ៉ាន់ត្រែ**	អត្តលេខ	៦៨២៨៩
៤-	ឧត្តមសេនីយ៍ត្រី	**ម៉ៅ ឋិសុត**	អត្តលេខ	៦៨៤០៤
៥-	ឧត្តមសេនីយ៍ត្រី	**ស៊ឹម ហុងហួត**	អត្តលេខ	៦៦៥៤៨
៦-	ឧត្តមសេនីយ៍ត្រី	**តិច សុខា**	អត្តលេខ	៨៤៥៥៥
៧-	ឧត្តមសេនីយ៍ត្រី	**ឃឹក ច័ន្ទរុក្ខា**	អត្តលេខ	៨៤៥៦៦
៨-	ឧត្តមសេនីយ៍ត្រី	**សុខ សុមនា**	អត្តលេខ	៨៥៨៨៨ ។

ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី

១- វរសេនីយ៍ឯក **យន សុផល** អត្តលេខ ៦៤៣៨០

២- វរសេនីយ៍ឯក **ជន សាឹងហ៊ីរ** អត្តលេខ ៦៧៥៩២ ។

មាត្រា ២ ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២០
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បន្ទាប់
ប្រមុខរដ្ឋស្តីទី

ចានណ. ២០០៤.៤៥៤

សម្តេចបិបុលសេនាតក្តី សាយ ឈុំ

ចានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៤២០/៤៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហនគូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦ករាជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្តាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិឧត្តមអគ្គានុរក្សពន្ធនាគារ ដល់មន្ត្រីពន្ធនាគារ **ចំនួន ០៤ រូប** នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ៖

១-	**លោក អោ ប៉ូឡែត**	អត្តលេខ ០១៨៨ ពីឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២
២-	**លោក អន សឆ្ឋារៈ**	អត្តលេខ ០២៣១ ពីឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២
៣-	**លោក ឈិន ឌ៉ាន**	អត្តលេខ ០២៤០ ពីឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២
៤-	**លោក ម៉ៅ ឌឿន**	អត្តលេខ ០៣០៧ ពីវរអគ្គានុរក្ស ថ្នាក់លេខ ១ មកជា ឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០២០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បន្តាប់
ប្រមុខរដ្ឋស្តីទី

M.is.

ចារណ.២០០៤.៤៥៥

សម្តេចវិបុលសេនាតក្តី សាយ ឈុំ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ត្រូវបានបង្កើតវិទ្យាស្ថានពហុបច្ចេកទេសកូមិភាគតេជោសែនកំពត ស្ថិតនៅក្រោមចំណុះរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរសេរជាអក្សរកាត់ថា **វ.ព.ភ.ក.ស.ព.** មានទីតាំងស្ថិតនៅភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត។

ជំពូកទី២
តួនាទីនិងភារកិច្ច

មាត្រា២ .-

វ.ព.ភ.ក.ស.ព. មានតួនាទីជាសេនាធិការឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងមានភារកិច្ច ដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីអប់រំនិងបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាព កម្រិតគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- កសាងនិងអនុវត្តផែនការអភិវឌ្ឍរបស់វិទ្យាស្ថានរយៈពេលខ្លី មធ្យម និងវែង
- សិក្សា ស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិនិងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេស និងប្រឹក្សាយោបល់ដល់មន្ត្រីនិងគ្រូបច្ចេកទេស
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន គ្រូបច្ចេកទេស កម្មករ សិក្ខាកាម សិស្ស និស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន
- ជ្រើសរើសសិក្ខាកាម សិស្ស និស្សិតឱ្យចូលរៀនតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ពីលទ្ធផលការងាររបស់វិទ្យាស្ថានជូនរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា៣ .-

វ.ព.ភ.ក.ស.ព. ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាលើកម្រិតជំនាញពាក់ព័ន្ធនឹងវិស័យអប់រំបណ្តុះបណ្តាលនិងវិជ្ជាជីវៈដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ឬ២ឆ្នាំ ឬក៏៣ឆ្នាំ ដែលមានយ៉ាងតិច៣០ក្រេឌីត សម្រាប់មួយកម្រិត
- កម្រិតសញ្ញាបត្រជាន់ខ្ពស់ឬបរិញ្ញាបត្ររង បច្ចេកទេសឬឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យាឬឯកទេសសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត។

យន្តការ នីតិវិធី និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជំពូកទី៣
ចេតនាសម្ព័ន្ធនិងការគ្រប់គ្រង

មាត្រា៤ .-

ទ.ព.ភ.ត.ស.ព. ត្រូវដឹកនាំដោយនាយក១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងនាយករងមួយចំនួន តែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ទ.ព.ភ.ត.ស.ព. មានដេប៉ាតឺម៉ង់និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់និងការិយាល័យចំណុះ **ទ.ព.ភ.ត.ស.ព.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា៥ .-

ទ.ព.ភ.ត.ស.ព. មានក្រុមប្រឹក្សាបច្ចេកទេសមួយដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ **ទ.ព.ភ.ត.ស.ព.**។

សមាសភាពនិងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា៦ .-

ទ.ព.ភ.ត.ស.ព. អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនសម្រាប់ជួយបំពេញការងារ។

មាត្រា៧ .-

ទ.ព.ភ.ត.ស.ព. មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

មាត្រា៨ .-

សិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យត្រូវទទួលបានវិញ្ញាបនបត្រឬសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រឬសញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ **ទ.ព.ភ.ត.ស.ព.** និងត្រូវទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជំពូកទី៤
ប្រភពធនធាន

មាត្រា៩ .-

ការចំណាយសម្រាប់ដំណើរការរបស់ **ទ.ព.ភ.ត.ស.ព.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ទ.ព.ភ.ត.ស.ព. មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

ជំពូកទី៥
អន្តរប្បញ្ញត្តិ

មាត្រា១០ .-

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការបង្កើតអង្គភាពនានាចំណុះ **ទ.ព.ភ.ត.ស.ព.** និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈបឹងនិមល ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា១១ .-

អនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ស្តីពីការប្រែក្លាយវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពតឱ្យទៅជាវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត ប្រកាសលេខ៣៣៩ ក.ប/ប្រក.គ.គ.ស ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាលរបស់សាលាបណ្តុះបណ្តាលវិជ្ជាជីវៈបឹងនិមល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤កើត ខែទុតិយាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ុត សំហេង

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឧត្តមក្រឹយសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ឧត្តមក្រឹយសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤០ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិក:ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈ-កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៤រូប ៖

១-ឧត្តមសេនីយ៍ទោ **លី គុនហុីយ** អត្តលេខ០៧៩០ ជាអគ្គលេខាធិការង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

២-ឧត្តមសេនីយ៍ត្រី **តែ សុថារេត** អត្តលេខ៨៣៨៨៣ ជាអគ្គលេខាធិការង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

៣-ឧត្តមសេនីយ៍ត្រី **សេក ស៊ីវ៉ែត** អត្តលេខ០៧០១៤ ជាជំនួយការ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន

៤-ឧត្តមសេនីយ៍ត្រី **កែវ ផល្លា** អត្តលេខ០៧៥៩៥ ជាជំនួយការ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

នាយកដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ធកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៣៤១ អនក្រ.ឥត

អនុក្រឹត្យ
ស្តីពីការតែងតាំងទីប្រឹក្សា
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈ-កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រី ដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **កែម សារ្យើន** ជាទីប្រឹក្សាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានឋានៈស្មើ អគ្គលេខាធិការរង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៦ឆ្ទុ ៧ រ៉ាត ខែ ៦ត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០

នាយកដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ធកាល័យសម្តេចតេជោនាយកដ្ឋមន្ត្រី
- ខុទ្ធកាល័យឧបនាយកដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៣៤៤...អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១: តែងតាំងមន្ត្រីរាជការចំនួន ០៣ រូប នៃអគ្គនាយកដ្ឋានគ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់ស៊ីវិទ្យុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដូចមានរាយនាមខាងក្រោមៈ

១- លោក **ចាន់ទី ពិសិដ្ឋ** ជាប្រធាននាយកដ្ឋានគោលនយោបាយ និងផែនការវិសាលគមន៍ហ្វ្រេកង់ស៊ីវិទ្យុ

២- លោក **វ៉ាយ ប៊ុនធឿន** ជាប្រធាននាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធហ្វ្រេកង់ស៊ីវិទ្យុ

៣- លោក **ភ្ងាច់ គឹមសាន** ជាប្រធាននាយកដ្ឋានគ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់ស៊ីវិទ្យុ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៦ស ៧ កើត ខែ ១៦ត្រ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៣៤៣...អនក្រ.តក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១: តែងតាំងលោកស្រី **ប៊ូ ស្រីលន់** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន របស់ក្រសួងផែនការ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៦ ខ្ទ ៧ ស៊ី ១ រោច ខែ ១ ច្រត ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឧទ្ធកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣៧៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១: តែងតាំងលោក **ជ័យ សុផារ៉េត** ជាទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឋានៈស្មើអគ្គនាយករង។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ថ្ងៃ ចន្ទ ៧ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៧៥ អនក្រ.ត៦

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យ លេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ស ម្រេ ច

មាត្រា ១: តែងតាំងមន្ត្រីរាជការចំនួន ០២ រូប នៃអគ្គាធិការដ្ឋាន នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានខាងក្រោម ៖

១-លោក **ឡេះ រ៉ានី** ជាអធិការ

២-លោក **សាន ឫណ្ណៈ** ជាអធិការ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ៦ ន្ទ ៧ កើត ខែ ឆេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ធកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៣៤៦...អនក្រ.ត.ត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .. តែងតាំងលោក **រាត សុពិសិដ្ឋ** ជាអធិការ នៃអគ្គាធិការដ្ឋាន នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា ២ .. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧ កើត ខែ ចិត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អន្លេងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ធកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤៧ សនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតាំងសិប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .. តាំងសិប់ក្នុងក្របខ័ណ្ឌដល់មន្ត្រីរាជការចំនួន ០៤ រូប ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម នៅក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ១៤ ខែ **មករា** ឆ្នាំ **២០២០** ដូចមានរាយនាមខាងក្រោម ៖

១- លោក **អន ពេជ្រមុន្នី** មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២- លោកស្រី **ប៊ុត ជាណា**	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ ៤
៣- លោក **លាង ច័ន្ទស្មី**	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ ៤
៤- លោកស្រី **ឈុំ សុភណ្ណារី**	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ ៤

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនអ្នចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៨ រោច ខែ ភទ្របទ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៦ ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៣៤៩...អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីលក្ខន្តិកៈដោយឡែកក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

សម្រេច

មាត្រា ១ .. តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន ៦៩ រូប នៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម របស់អាជ្ញាធរសវនកម្មជាតិ ចាប់ពីថ្ងៃទី ១៣ ខែ **មេសា** ឆ្នាំ ២០២០ ដូចមានរាយនាមខាងក្រោម ៖

១.	ណេក **ហេង ចាន់ថន**	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២.	ណេក **លឹម ឃុនសុភ័ក្រ**	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣.	ណេក **រ៉ា បូរឹទ្ធ**	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤.	ណេក **លុយ សុភាទី**	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១

៥.	លោកស្រី ឈឹម រដ្ឋា	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៦.	លោកស្រី នុត ធាវី	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៧.	លោក ម៉ាន់ ធីវ័ន្ត	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៨.	លោក ឈឹម សេង	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៩.	លោក ឡុង នីលវ័ត្ត	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១០.	លោក ខន ជានេត	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១១.	លោក សុខ ធារ៉ា	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១២.	លោក ឡាយ សិរីពេជ្យ	ពីសវនករដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៣.	ឯកឧត្តម ឌី ភណ្ណឌី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៤.	លោក សិទ្ធិ បញ្ញាឫទ្ធិ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៥.	លោកស្រី ហេង ម៉ូនីតា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៦.	លោក ភក្ត្យ ឥចិត្រ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៧.	លោកស្រី រៀន សារ៉ុម	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៨.	លោក ហាន ច័ន្ទណារិទ្ធ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៩.	លោកជំទាវ ម៉ម រមនា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២០.	លោក ឡោក ជំនាញ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២១.	លោក ធម្ម ប៊ុណ្ណារីនេ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២២.	លោក សេង ធីរិទ្ធ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២៣.	លោក ភេង ឥសាល	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២៤.	លោក ហេង ស៊ុនតារា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២៥.	លោក ហាស់ ឥចិត្រ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២៦.	លោក ឆាយ ភណ្ណឥសិទ្ធិ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២៧.	លោក រៀច សុភណ្ណច័ន្ទត្រា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២៨.	លោក ខន គុចហ៊ាង	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២៩.	លោកស្រី ប៉ុល សុផល	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣០.	លោក ប៉ែន ច័ន្ទរិទ្ធី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣១.	លោក ជួង សុធារតន៍	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣២.	លោកស្រី ឃុន ពិជោរ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣៣.	លោក ឈូក សុខសាន្ត	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣៤.	លោក ណុប ស៊ីណា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣៥.	លោក ឆៃ ចំរើន	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣៦.	លោក ថាម សុខគង់	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២

៣៧.	លោកស្រី អ៊ុំ រស្មី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣៨.	លោក ឆាក់ រចនា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣៩.	លោកស្រី ប៊ុន ស៊ីណែត	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤០.	លោកស្រី ភូថ សុភា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤១.	លោក ឌឹម ម៉ូរ៉ា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤២.	លោកស្រី ថេត ថារី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៣.	លោក ប៉ា សុថារី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៤.	លោក ហា ង៉ាន់ដា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៥.	លោក អ៊ុំច សំឃរ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៦.	លោក យ៉ែម ភូរិទ្ធ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៧.	លោក លឹម ឡុចឌី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៨.	លោក លី សុចហួរ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៩.	លោក ង៉ន ឌីរៈ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥០.	លោក ហែម ឥមល	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥១.	លោក ប្រាជ្ញ ឈៀងលី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥២.	លោក ប៊ុន ឥណ្ណារិទ្ធ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៣.	លោក អ៊ុំច សំអាន	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៤.	លោស្រី ង៉ាន់ ចានី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៥.	លោក សូណា សាន់ដេ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៦.	លោក សេង កុសល	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៧.	លោក សុខ ឌីរៈ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៨.	លោកស្រី យ៉ែត ម៉ូលិះ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៩.	លោក កុយ មករា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦០.	លោក ហ៊ឹម សុគន្ធា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦១.	លោកស្រី ហ៊ាង សុជាតា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦២.	លោក អ៊ុក ឌីរៈ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៣.	លោក ប៉ែន ជាណា	ពីសវនករដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៤.	លោក សោម ប៉ាត្រី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៦៥.	លោកស្រី ឌី ស្រីអន	ពីសវនករដើមខ្សែ ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៦៦.	លោក ហ៊ាល ផល្លីន	ពីសវនករដើមខ្សែ ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៦៧.	លោកស្រី ថន ម៉ាជានី	ពីសវនករដើមខ្សែ ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៦៨.	លោក សុក សុតភ្ពិ	ពីសវនករដើមខ្សែ ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣

៦៩. លោកស្រី **ឈន ចិមល** ពីសវនករ ថ្នាក់លេខ១ មកជាសវនករដើមខ្សែ ថ្នាក់លេខ៤

មាត្រា ២ .. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧ កើត ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

នាយកដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣៤៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .. តែងតាំងលោក **គឹង ការ៉ូឌី** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

មាត្រា ២ .. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៥ឆ្ម ៧ ឯកស ខែ ៤៥ត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឯ ឆ្នាំ ២០២០

នាយកដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៣៣០...អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការធ្វើនិយ័តកម្មតម្លើចក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .. និយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ និងកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន ០៦ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ នៅក្រសួង ស្ថាប័នចំនួន ០៣ ដូចមានរាយនាមខាងក្រោម ៖

ក/-ក្រសួងធនធានទឹក និងឧតុនិយម

១-លោក **អ៊ុច ហ៊ុង**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ១
២-លោក **ស៊ិន សេរី**	ពីអនុមន្ត្រី ថ្នាក់លេខ ២	មកជាវរមន្ត្រី ថ្នាក់លេខ ១

ខ/-ក្រសួងផែនការ

១-លោក **រស់ ឌិរិយធន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ១
២-លោកស្រី **ឌឹម ចរិយា**	ពីអនុមន្ត្រី ថ្នាក់លេខ ២	មកជាវរមន្ត្រី ថ្នាក់លេខ ២
៣-លោកស្រី **កាន់ សុភ័ណ្ឌា**	ពីអនុមន្ត្រី ថ្នាក់លេខ ៣	មកជាវរមន្ត្រី ថ្នាក់លេខ ៣

គ/-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

១-លោក **សុខ ច័ន្ទមុនី**	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៨ មកជាក្រមការដើមខ្សែ ថ្នាក់លេខ ៤

មាត្រា ២ .. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧ កើត ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឯសា ឆ្នាំ ២០២០

នាយកដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញា*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាត់ណា
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនាឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១. បំពាក់មេដាយ **មុនីសារាត់ណា** ថ្នាក់ **ចិបឌិន្ន** ជូនសប្បុរសជន ចំនួន ២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសាលាអាន់ ព្រះវិហារ កុដិ របងវត្ត ខ្លោងទ្វារ នៅវត្តជីឥង្ហ ឃុំជីឥង្ហ ស្រុកកៀនស្វាយ ខេត្តកណ្តាលកន្លងមក ដូចមានរាយនាមខាងក្រោម៖

១-	លោក	សំ ផុន	សប្បុរសជន
២-	ឧបាសិកា	ង៉ាន់ សុខមុំ	សប្បុរសជន

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

កន្លែងទទួល៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ថ្ងៃ ២៨ ៧ កើត ខែ ១២ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣២ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

